ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ច្បាប់
# ស្តីពី
# គយ

ចែករំលែកដោយៈ មេធាវីតម្រាច្បាប់
www.legalcodecambodia.com
www.facebook.com/legalcodelawoffice
**App Store & Play Store : LEGAL CODE LIBRARY (បណ្ណាល័យតម្រាច្បាប់)**

នស/រកម/០៧០៧/០១៧

# ព្រះរាជក្រម

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរាជរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីគយ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៧ នាសម័យប្រជុំរដ្ឋសភាលើកទី ៦ នីតិកាលទី៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៧ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី៣ នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL * ព្រះបរមរាជវាំង
2/45

# ច្បាប់

# ស្តីពី

# គយ

ROYAUME DU CAMBODGE * LE MINISTÈRE DU PALAIS ROYAL

# ជំពូកទី ១

# បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

គោលបំណងនៃច្បាប់នេះគឺ :

-ផ្តល់សិទ្ធិគ្រប់គ្រង ត្រួតពិនិត្យ ប្រមូលពន្ធ អាករ និងកម្រៃផ្សេងៗលើទំនិញនាំចេញ ឬ នាំចូល

-ផ្តល់សិទ្ធិដាក់បទប្បញ្ញត្តិលើការធ្វើចរាចរ ការធ្វើសន្និធិ និងការដឹកជញ្ជូនឆ្លងកាត់នៃទំនិញនាំចេញ ឬ នាំចូល

-ជំរុញការបង្ការ និងបង្ក្រាបអំពើល្មើស និងអំពើរត់ពន្ធ

-ចូលរួមអនុវត្តគោលនយោបាយពាណិជ្ជកម្មអន្តរជាតិរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-ជំរុញនូវការអនុវត្តតាមស្តង់ដាអន្តរជាតិ និងការអនុវត្តល្អប្រសើរដែលពាក់ព័ន្ធទៅនឹងការត្រួតពិនិត្យគយ និងការសម្រួលពាណិជ្ជកម្ម ។

ទីចាត់ការគយ និងរដ្ឋាករជាស្ថាប័នទទួលខុសត្រូវក្នុងការគ្រប់គ្រង និងការអនុវត្តតាមបញ្ញត្តិនៃច្បាប់នេះ ។ ស្ថាប័ននេះស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

**មាត្រា ២.-**

ដែនគយមាន ដែនដី ដែនទឹក ដែនអាកាស និងកោះនានានៃព្រះរាជាណាចក្រកម្ពុជា ។ រាជរដ្ឋាភិបាលមានសិទ្ធិបង្កើតតំបន់រួចពន្ធនានា ដែលមិនស្ថិតនៅក្រោមការអនុវត្តទាំងស្រុង ឬ ភាគខ្លះនូវនីតិវិធីគយ ។

**មាត្រា ៣.-**

ច្បាប់នេះត្រូវអនុវត្ត :

-ដូចគ្នានៅក្នុងដែនគយទាំងមូល

-ស្មើភាពដោយឥតយោគយល់ចំពោះបុគ្គលណាឡើយ

-ដោយពុំមានផ្តល់នូវអភ័យឯកសិទ្ធិ ឬ ឱ្យរួចផុតពីការអនុវត្តនៃច្បាប់នេះ ចំពោះទំនិញនាំចេញ និងនាំចូល ដោយក្នុងនាមរដ្ឋ ។

**មាត្រា ៤.-**

ប្រតិបត្តិការគយត្រូវប្រព្រឹត្តនៅក្នុងដែនគយទាំងមូល រាប់បញ្ចូលទាំងវង់អំណាចគយតាមបណ្តោយព្រំដែនគោក និងតំបន់ឆ្នេរ ក្រោមល័ក្ខខ័ណ្ឌដែលមានចែងនៅក្នុងច្បាប់នេះ ។

វង់អំណាចគយមានមណ្ឌលសមុទ្រ និងមណ្ឌលដីគោក :

ក-មណ្ឌលសមុទ្រមានព្រំដែនពីឆ្នេរទៅក្រៅចម្ងាយម្ភៃ (២០) គីឡូម៉ែត្រ ។

ខ-មណ្ឌលដីគោកលាតសន្ធឹង :

-ពីឆ្នេរសមុទ្រចូលមកក្នុងចម្ងាយម្ភៃ (២០) គីឡូម៉ែត្រ ព្រមទាំងដីចម្ងាយម្ភៃ (២០) គីឡូម៉ែត្រ ពីមាត់ទន្លេ មាត់ស្ទឹង មាត់ព្រែក ដែលហូរចាក់ទៅសមុទ្រមកទល់នឹងការិយាល័យគយនៅដើមគេបង្អស់ គិតពីសមុទ្រមក និងរង្វង់ម្ភៃ (២០) គីឡូម៉ែត្រជុំវិញការិយាល័យនេះ ។

-តាមព្រំដែនគោកចូលមកខាងក្នុងចម្ងាយម្ភៃ(២០) គីឡូម៉ែត្រ ។

ដើម្បីឱ្យងាយស្រួលដល់ការបង្ក្រាបបទល្មើស រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចចេញប្រកាស :

ក-ពង្រីកជម្រៅមណ្ឌលដីគោករហូតដល់ហុកសិប (៦០) គីឡូម៉ែត្រ សម្រាប់ទីកន្លែង និងរយៈពេលកំណត់មួយ ។

ខ-កំណត់វង់អំណាចគយរហូតដល់បី (៣)គីឡូម៉ែត្រ ជុំវិញការិយាល័យគយដែលមិនស្ថិតក្នុងវង់អំណាចដូចមានចែងក្នុងកថាខណ្ឌទី ១ កថាខណ្ឌទី ២ និងវាក្យខណ្ឌ ក កថាខណ្ឌទី ៣ នៃមាត្រានេះ ។

ទោះបីជាមានបញ្ញត្តិដូចមានចែងនៅក្នុងកថាខណ្ឌទី ១ នៃមាត្រា នេះក៏ដោយរាជរដ្ឋាភិបាលអាចចេញអនុក្រឹត្យ :

ក-ចាត់តាំងឱ្យមន្ត្រីគយអនុវត្តការងាររបស់ខ្លួន ដូចមានចែងនៅក្នុងច្បាប់នេះ នៅក្រៅដែនគយ ដោយឈរលើមូលដ្ឋានបដិការ និង អនុលោមតាមកិច្ចព្រមព្រៀង



4/45

អន្តរជាតិ សន្ធិសញ្ញា ឬ អនុសញ្ញាដែលព្រះរាជាណាចក្រកម្ពុជាបានចូលរួម ។

ខ-អនុញ្ញាតឱ្យមន្ត្រីគយនៃប្រទេសដទៃអនុវត្តការងាររបស់ខ្លួន ដូចមានចែងនៅក្នុងច្បាប់របស់ប្រទេសទាំងនោះ ដែលពាក់ព័ន្ធទៅនឹងការនាំចូល និងនាំចេញទំនិញនៅក្នុងដែនគយ ដោយឈរលើមូលដ្ឋានបដិការ និង អនុលោមតាមកិច្ចព្រមព្រៀងអន្តរ-ជាតិ សន្ធិសញ្ញា ឬ អនុសញ្ញាដែលព្រះរាជាណាចក្រកម្ពុជាបានចូលរួម ។

ទម្រង់ការគយអាចនឹងបំពេញបានតែក្នុងការិយាល័យគយ លើកលែងតែមានការកំណត់ដោយឡែក ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

ប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ កំណត់ការបង្កើត កិច្ចដំណើរការ និងការលុបចោលការិយាល័យគយ ។

ពេលម៉ោងធ្វើការរបស់ការិយាល័យគយ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់នាយកទីចាត់ការគយ និងរដ្ឋាករ ។ សេចក្តីសម្រេចនេះត្រូវបិទផ្សាយនៅតាមការិយាល័យគយនីមួយៗ ។

## មាត្រា ៥.-

ទំនិញនាំចេញ ឬនាំចូលទាំងអស់ គឺជាកម្មវត្ថុនៃការអនុវត្តតាមបញ្ញត្តិនៃច្បាប់នេះ ។

ទំនិញទាំងឡាយដែលចូលមកក្នុង ឬ ចេញពីដែនគយ ត្រូវជាប់ពន្ធនាំចូល ឬ នាំចេញ និងអាករ ដូចមានចែងក្នុងតារាងពន្ធគយ ។ បែបបទស្តីពីការរៀបចំ និងការអនុវត្តតារាងពន្ធគយត្រូវចែងលំអិតនៅក្នុងអនុក្រឹត្យ ។

ក្នុងករណីមានពាក់ព័ន្ធនឹងផលប្រយោជន៍ជាតិ រាប់បញ្ចូលទាំងករណីមានភាពអាសន្ន រាជរដ្ឋាភិបាលអាចចេញបញ្ជាឱ្យផ្អាកទាំងស្រុង ឬ ភាគខ្លះនូវពន្ធ និងអាករលើទំនិញសម្រាប់ជាតម្រូវការរបស់ប្រជាពលរដ្ឋ ឬ ផ្អាកការនាំចេញ ឬ ការនាំចូលនូវទំនិញប្រភេទខ្លះ ។

## មាត្រា ៦.-

ពន្ធគយអនុគ្រោះអាចផ្តល់ជូនបាន ប្រសិនបើមានចែងក្នុងការសន្យា កិច្ចព្រមព្រៀង សន្ធិសញ្ញា ឬ អនុសញ្ញាអន្តរជាតិដែលព្រះរាជាណាចក្រកម្ពុជាបានចូលរួម ។ ពន្ធគយអនុគ្រោះដែលចេញមកពីកាតព្វកិច្ចក្រោមការសន្យា កិច្ចព្រមព្រៀង សន្ធិសញ្ញា ឬ អនុ-សញ្ញាអន្តរជាតិទាំងនេះ ត្រូវកំណត់ដោយអនុក្រឹត្យ ។



5/45

**មាត្រា ៧.–**

រាជរដ្ឋាភិបាលអាចកំណត់បានដោយអនុក្រឹត្យចាត់វិធានការចាំបាច់នានារាប់បញ្ចូលទាំងការដំឡើងអត្រាពន្ធ ដើម្បីការពារផលិតករកម្ពុជា នៅពេលដែលផលិតករក្នុងស្រុកត្រូវទទួលរងគ្រោះដោយកំណើននៃការនាំចូល ឬ ដោយឧបត្ថម្ភធនដែលបានផ្តល់ដោយរដ្ឋាភិបាលនៃប្រទេសផ្សេងទៀត ចំពោះការនាំចេញផលិតផលរបស់ខ្លួនមកកម្ពុជា ឬ ដោយការលក់បង្ខូចថ្លៃទំនិញនៅលើទីផ្សារកម្ពុជា ។

**មាត្រា ៨.–**

រាជរដ្ឋាភិបាលអាចកំណត់បានដោយអនុក្រឹត្យនូវមុខទំនិញមួយចំនួនឱ្យជាប់អាជ្ញាប័ណ្ណ ឬ កម្រិតកំណត់ក្រោមល័ក្ខខ័ណ្ឌលើការនាំចេញ ឬ នាំចូលក្នុងគោលបំណងណាមួយដូចតទៅ :

-សន្តិសុខជាតិ

-សណ្តាប់ធ្នាប់សាធារណៈ និងតាមស្តង់ដានៃសុភាវធម៌ និង សីលធម៌

-ការការពារសុខភាព និង ជីវិតមនុស្ស សត្វ ឬ រុក្ខជាតិ

-ការការពារបេតិកភណ្ឌជាតិ ដែលមានតម្លៃខាងសិល្បៈ ប្រវត្តិសាស្ត្រ ឬ បុរាណវត្ថុវិទ្យា

-ការអភិរក្សធនធានធម្មជាតិ

-ការតម្រូវតាមបញ្ញត្តិនានានៃច្បាប់ណាមួយជាធរមាននៃព្រះរាជាណាចក្រកម្ពុជា

-ការបំពេញកាតព្វកិច្ចក្រោមធម្មនុញ្ញសហប្រជាជាតិ ។

ដើម្បីប្រយុទ្ធប្រឆាំងអំពើល្មើសនិងអំពើរត់ពន្ធ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុអាចចេញប្រកាសកំណត់នូវមុខទំនិញមានវេទយិតភាព ឬ ទំនិញដែលជាប់ពន្ធខ្ពស់ជាទំនិញកំណត់ពិសេស សម្រាប់គោលបំណងនៃច្បាប់នេះ ហើយអាចកំណត់បន្ថែមលើការត្រួតពិនិត្យ និងការដាក់កម្រិតបានលើការដឹកជញ្ជូន ចរាចរ សន្និធិ និងការកាន់រក្សាទំនិញទាំងនេះ ។

**មាត្រា ៩.–**

លើកលែងតែបរិបទតម្រូវផ្សេងពីនេះ សម្រាប់គោលបំណងនៃច្បាប់នេះ :

- **ពន្ធគិតតាមតម្លៃ "Ad Valorem duty"** គឺជាពន្ធដែលគណនាដោយផ្អែកលើមូលដ្ឋាននៃតម្លៃគិតពន្ធគយ ។

- **ពន្ធគិតតាមឯកតា** គឺជាពន្ធដែលគណនាផ្អែកតាមឯកតា ទម្ងន់ ចំណុះ ឬ បរិមាណនៃទំនិញ ។

- **អគ្គាគារគយមានដែនកំណត់** គឺជាអគារ ទីកន្លែង ឬ ទីលានណាមួយដែលបំពេញគ្រប់ល័ក្ខខ័ណ្ឌ ដែលកំណត់ដោយរដ្ឋបាលគយ សម្រាប់បម្រើដល់ការធ្វើសន្និធិ ការកែច្នៃ ការតាំងបង្ហាញសម្រាប់លក់ ឬ សម្រាប់គោលបំណងពាក់ព័ន្ធផ្សេងទៀត ដែលទំនិញត្រូវព្យួរពន្ធ និងអាករ ជាបណ្ដោះអាសន្ន ។

- **មធ្យោបាយដឹកជញ្ជូន** គឺជាជលយាន អាកាសយាន ឬ មធ្យោបាយផ្សេងទៀត ដែលប្រើប្រាស់សម្រាប់ដឹកជញ្ជូនមនុស្ស ឬ ទំនិញ ។

- **ការរត់ពន្ធ** គឺជាការនាំចេញ ឬ នាំចូលទំនិញនៅក្រៅការិយាល័យគយព្រមទាំងការបំពានលើបញ្ញត្តិច្បាប់ ឬ បទបញ្ញាដែលទាក់ទងដល់ការនាំចេញ ឬ នាំចូល ការកាន់កាប់ និងការដឹកជញ្ជូនទំនិញនៅក្នុងផ្ទៃនៃដែនគយ ។

- **ប្រទេសដើមកំណើត** គឺជាប្រទេសដែលទំនិញត្រូវបានផលិត ឬ កែច្នៃស្របតាមលក្ខណៈវិនិច្ឆ័យ ដែលមានចែងសម្រាប់ជាគោលបំណងនៃការប្រើប្រាស់តារាងពន្ធគយ ស្របតាមការកម្រិតកំណត់លើបរិមាណ ឬ ករណីផ្សេងទៀតដែលពាក់ព័ន្ធនឹងវិស័យពាណិជ្ជកម្ម ។

- **គយ ឬ រដ្ឋបាលគយ** គឺសំដៅលើទីចាត់ការគយ និងរដ្ឋាករនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយរាប់បញ្ចូលមន្ត្រីគយដែលទទួលខុសត្រូវក្នុងការគ្រប់គ្រងត្រួតពិនិត្យការអនុវត្តច្បាប់គយ ការប្រមូលពន្ធ អាករ និងកម្រៃផ្សេងៗ ព្រមទាំងទទួលខុសត្រូវផងដែរក្នុងការអនុវត្តច្បាប់ និង បទប្បញ្ញត្តិផ្សេងទៀត ដែលទាក់ទងនឹងការនាំចេញ ឬ នាំចូល ចរាចរ និង សន្និធិទំនិញ ។

- **ជើងសារគយ** គឺជាបុគ្គលដែលបានទទួលការអនុញ្ញាតតាមផ្លូវច្បាប់ ដើម្បីធ្វើ

អាជីវកម្មបំពេញបែបបទបញ្ចេញទំនិញពីគយដោយផ្ទាល់ជាមួយរដ្ឋបាលគយ ក្នុងនាមបុគ្គលផ្សេងទៀត ។

**-ការបំពេញបែបបទបញ្ចេញទំនិញពីគយ** គឺជាការបំពេញនូវទម្រង់ការគយចាំបាច់នានា ដើម្បីទទួលបានការអនុញ្ញាតឱ្យទំនិញអាចដាក់ឱ្យប្រើប្រាស់បានក្នុងប្រទេស អាចឱ្យនាំចេញ ឬ ដាក់ក្រោមរបបគយមួយផ្សេងទៀតបាន ។

**-កន្លែងបំពេញបែបបទបញ្ចេញទំនិញពីគយ** គឺជាកន្លែងដែលស្ថិតនៅក្រោមការគ្រប់គ្រង ការឃ្លាំមើលដោយរដ្ឋបាលគយ ។

**-ការត្រួតពិនិត្យគយ** គឺជានីតិវិធីដែលកំណត់ដោយរដ្ឋបាលគយលើការដឹកជញ្ជូន ចរាចរ និងសន្និធិទំនិញនាំចេញ ឬ នាំចូល ។

**-ប្រតិវេទន៍គយ** គឺជាសេចក្ដីប្រកាសដែលធ្វើឡើង សម្រាប់គោលបំណងនៃការនាំចេញ ឬ នាំចូល តាមទម្រង់ និងរបៀបដូចមានចែងក្នុងច្បាប់នេះ ។

**- ការពិនិត្យឆែកឆេររបស់គយ** គឺជាការធ្វើអធិការកិច្ចជារូបវ័ន្តលើទំនិញ ឬ ឯកសារដោយរដ្ឋបាលគយ ដើម្បីបញ្ជាក់យថាប្រភេទ ដើមកំណើត ល័ក្ខខ័ណ្ឌ បរិមាណ និងតម្លៃទំនិញ សមស្របតាមការប្រកាសនៅក្នុងប្រតិវេទន៍គយ ។

**- ទម្រង់ការគយ** គឺជាប្រតិបត្តិការដែលត្រូវអនុវត្តដោយបុគ្គលពាក់ព័ន្ធ និងដោយរដ្ឋបាលគយក្នុងគោលបំណងគោរពតាមច្បាប់នេះ និងច្បាប់ផ្សេងទៀតដែលរដ្ឋបាលគយមានភារៈចាត់ចែងគ្រប់គ្រង និងអនុវត្ត ។

**-តំណាគារផលិតកម្មមានដែនកំណត់ស្ថិតក្រោមការគ្រប់គ្រងរបស់គយ** គឺជារោងចក្រដែលស្ថិតក្រោមការត្រួតពិនិត្យរបស់គយ លើទំនិញនាំចូលដោយលើកលែងជាបណ្ដោះអាសន្ននូវពន្ធ និងអាករនានា សម្រាប់ប្រើប្រាស់ក្នុងដំណើរការផលិតកម្ម ។

**- ការិយាល័យគយ** គឺជាអង្គភាពរដ្ឋបាលគយដែលមានសមត្ថកិច្ចគ្រប់គ្រង ត្រួតពិនិត្យ ទម្រង់ការគយ អគារ ឬ ទីតាំងផ្សេងទៀតដែលទទួលការអនុញ្ញាតសម្រាប់គោលបំណងនៃបទប្បញ្ញត្តិច្បាប់នេះ ។

**- មន្ត្រីគយ** គឺជាជនដែលបានទទួលសិទ្ធិក្នុងការចាត់ចែង គ្រប់គ្រង និងអនុវត្តច្បាប់នេះ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
ក្រសួងព្រះបរមរាជវាំង



8/05

- **តម្លៃគិតពន្ធគយ ឬ តម្លៃ** ពាក់ព័ន្ធទៅនឹងទំនិញនាំចូល គឺជាតម្លៃគិតពន្ធគយនៃទំនិញទាំងនោះដែលត្រូវបានកំណត់ស្របតាមមាត្រា ២១ នៃច្បាប់នេះ ។

- **ប្រតិវេទនករ** គឺជាបុគ្គលដែលធ្វើការប្រកាសដល់គយក្នុងនាមខ្លួនផ្ទាល់ ឬ ក្នុងនាមអ្នកដទៃ ។

- **ឯកសារ** គឺជាឯកសារតាមទម្រង់ណាមួយ ទោះជាមាន ឬ គ្មានចុះហត្ថលេខា ឬ ចុះអាទិសង្កេត ឬធ្វើយថាភូតដោយអ្នកតាក់តែង និងរាប់បញ្ចូលទាំង :

-ទម្រង់ណាមួយដែលសរសេរលើសម្ភារៈ

-ព័ត៌មានថតទុក បញ្ជូន ឬ រក្សាទុកដោយមធ្យោបាយនានា ដូចជា : ឧបករណ៍ថត កុំព្យូទ័រ ឬឧបករណ៍ផ្សេងទៀត និងសម្ភារៈដែលយកចេញពីព័ត៌មានទាំងនេះ ។

-ស្លាក ឬ សញ្ញាសម្គាល់ផ្សេងទៀត ឬ ការសរសេរដែលភ្ជាប់នឹងវត្ថុអ្វីមួយ ឬ សម្ភារៈជាភាគណាមួយនៃវត្ថុនោះ ។

-សៀវភៅ ផែនទី ប្លង់ ក្រាហ្វ ឬ គំនូរ

-រូបថត ហ្វីល ខ្សែអាត់ ឬឧបករណ៍ផ្សេងទៀតដែលផ្ទុកនូវរូបភាពហើយមានលទ្ធភាពអាចធ្វើការផ្តិតចម្លងបាន ។

- **ពន្ធ** គឺជាពន្ធ ពន្ធបន្ថែម អាករ កម្រៃ ឬ បន្ទុកផ្សេងទៀតដែលយកលើទំនិញស្របតាមបញ្ញត្តិណាមួយនៃច្បាប់នេះ ឬ ច្បាប់ និងបទប្បញ្ញត្តិផ្សេងទៀតដែលអនុវត្ត និងគ្រប់គ្រងដោយគយ ។

- **តំបន់រួចពន្ធ** គឺជាតំបន់បង្កើតឡើងដោយរាជរដ្ឋាភិបាល ដែលទំនិញនាំចូលពុំមែនជាកម្មវត្ថុនៃការជាប់ពន្ធ និងអាករក្រោមល័ក្ខខ័ណ្ឌកំណត់ច្បាស់លាស់ ។

- **ទំនិញ** គឺជាចលនទ្រព្យទាំងឡាយ ។

- **ការដាក់ឱ្យប្រើប្រាស់ក្នុងប្រទេស** គឺជាការចរាចរទំនិញនាំចូលដោយសេរីក្នុងរង្វង់ដែនគយ បន្ទាប់ពីបានបញ្ចេញទំនិញពីគយ ។

- **អ្នកនាំចូល** គឺជាបុគ្គលដែលនាំចូលទំនិញដោយខ្លួនឯង ឬ ដោយអ្នកដទៃ ។ ត្រូវចាត់ជាអ្នកនាំចូលផងដែរនូវអ្នកទទួលទំនិញ បុគ្គលដែលជាម្ចាស់កម្មសិទ្ធិ បុគ្គលដែលនឹងទៅជាម្ចាស់កម្មសិទ្ធិ ឬ អ្នកមានសិទ្ធិចាត់ចែងលើកម្មសិទ្ធិទំនិញទាំងនោះ មុនពេលដែលទំនិញនោះ ឈប់ជាកម្មវត្ថុនៃការត្រួតពិនិត្យគយ ។



9/45

- **ការនាំចូល** ពាក់ព័ន្ធទៅនឹងទំនិញ គឺជាការមកដល់ដែនគយនូវទំនិញតាមរបៀបណាក៏ដោយ ទោះជាស្របច្បាប់ ឬមិនស្របច្បាប់ពីចំណុច ឬ ទីកន្លែងនៅក្រៅដែនគយ ។

- **ការអនុញ្ញាតឱ្យយកចេញ** គឺជាការអនុញ្ញាតរបស់គយឱ្យយកទំនិញដែលបានបំពេញបែបបទគយរួចចេញពីការគ្រប់គ្រងរបស់គយដល់បុគ្គលពាក់ព័ន្ធ ។

- **និម្មិត្តធានា** គឺជាការធានាផ្នែកហិរញ្ញវត្ថុ ឬ លិខិតុបករណ៍ហិរញ្ញវត្ថុផ្សេងទៀត ដែលប្រើប្រាស់សម្រាប់ធានាក្នុងការទូទាត់បង់ពន្ធ អាករ និងកម្រៃផ្សេងទៀតជាយថាហេតុតាមបញ្ញត្តិនៃច្បាប់នេះ ។

- **ទំនិញកំណត់ពិសេស** គឺជាទំនិញទាំងឡាយដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុតាមកថាខណ្ឌទី ២ ក្នុងមាត្រា ៨ នៃច្បាប់នេះ ។

- **តម្រាយផ្លូវស្របច្បាប់** គឺជាផ្លូវគោក ផ្លូវដែក ផ្លូវទឹក និងផ្លូវផ្សេងទៀតណាមួយដែលគយកំណត់ឱ្យប្រើប្រាស់ សម្រាប់ការដឹកជញ្ជូនទំនិញនាំចេញ ឬ នាំចូលក្រោមការគ្រប់គ្រង និងត្រួតពិនិត្យរបស់គយ ។

- **ប្របទេសន៍កាលិក** គឺជានីតិវិធីគយ ដែលអាចអនុញ្ញាតឱ្យទំនិញនាំចូលបានក្នុងដែនគយក្រោមល័ក្ខខ័ណ្ឌរួចផុតពីការបង់ពន្ធ និងអាករទាំងស្រុង ឬ ភាគខ្លះ ។ ទំនិញទាំងនោះត្រូវបាននាំចូលក្នុងគោលបំណងច្បាស់លាស់ ហើយត្រូវនាំចេញទៅវិញក្នុងកម្រិតពេលវេលាជាក់លាក់មួយ និងមិនធ្វើការ កែច្នៃ ឬ ផ្លាស់ប្តូរ លើកលែងតែការរិលស់ជាធម្មតាតាមការប្រើប្រាស់ ។

- **ការឆ្លងកាត់** គឺជានីតិវិធីគយ ដែលអនុញ្ញាតឱ្យដឹកជញ្ជូនទំនិញពីការិយាល័យគយមួយទៅការិយាល័យគយមួយទៀត ក្រោមការត្រួតពិនិត្យរបស់គយ ។

- **ការផ្ទេរមធ្យោបាយដឹកជញ្ជូន** គឺជានីតិវិធីគយ ដែលអនុញ្ញាតឱ្យផ្ទេរទំនិញពីមធ្យោបាយដឹកជញ្ជូននាំចូល ទៅមធ្យោបាយដឹកជញ្ជូននាំចេញ ក្រោមការត្រួតពិនិត្យរបស់គយនៅក្នុងរង្វង់ការិយាល័យគយតែមួយ ដែលជាការិយាល័យនៃការនាំចូល និងការនាំចេញ ។

- **ការដឹកជញ្ជូនត្រង់** គឺជាការដឹកជញ្ជូនជាអន្តរជាតិនូវទំនិញពីប្រទេសដើម



ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL · ក្រសួងព្រះបរមរាជវាំង

10/45

កំណើតទំនិញនោះទៅប្រទេសនាំចូល ដោយមិនមានការឆ្លងកាត់ប្រទេសដទៃ ក្រៅពីប្រទេសដើមកំណើតទំនិញ និងប្រទេសគម្មផ្ទាន លើកលែងតែការឆ្លងកាត់នេះត្រូវបានធ្វើដោយសារលក្ខណៈភូមិសាស្ត្រ ឬ ចលនូបត្ថម្ភ ហើយទំនិញទាំងនោះមិនស្ថិតនៅក្នុងពាណិជ្ជកម្ម ឬការប្រើប្រាស់ និងមិនត្រូវរងនូវប្រតិបត្តិការណាមួយក្រៅពីការលើកដាក់ ឬ ប្រតិបត្តិការដើម្បីថែរក្សាទំនិញទាំងនោះឱ្យបានប្រសើរនៅប្រទេសដែលបានឆ្លងកាត់នោះ ។

- **បុគ្គល** គឺជារូបវន្តបុគ្គល ឬ នីតិបុគ្គល ។

## ជំពូកទី ២

## ការនាំចូល និងការនាំចេញ

### ផ្នែកទី ១

### ការនាំចូល

**មាត្រា ១០.-**

ទំនិញនាំចូលទាំងអស់ត្រូវបានរាយការណ៍នៅការិយាល័យគយ ឬ ទីកន្លែងផ្សេងទៀតទៅតាមការកំណត់របស់នាយកទីចាត់ការគយ និងរដ្ឋាករ ។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវចេញប្រកាសកំណត់ពេលវេលា របៀបរបប តម្រូវការ ឯកសារ កាលៈទេសៈ និងការលើកលែងនានាពាក់ព័ន្ធនឹងការរាយការណ៍ពីទំនិញនាំចូល ។

**មាត្រា ១១.-**

ទំនិញនាំចូលទាំងអស់ត្រូវបានរាយការណ៍នៅការិយាល័យគយដែលជិតបំផុតតាមតម្រោយផ្លូវស្របច្បាប់ :

ក-ក្នុងករណីទំនិញដែលកាន់រក្សាដោយជនណាម្នាក់ ដែលបានមកដល់កម្ពុជា ឬ ជាផ្នែកនៃអីវ៉ាន់ផ្ទាល់ខ្លួន ត្រូវរាយការណ៍ដោយជននោះ ។

ខ-ក្នុងករណីទំនិញដែលបាននាំចូលដោយសេវាកម្មបញ្ញើ ឬ តាមរយៈបញ្ញើប្រៃសណីយ៍ត្រូវរាយការណ៍ដោយបុគ្គលដែលបាននាំចេញទំនិញនោះមកកម្ពុជា ។

គ-ក្នុងករណីទំនិញដែលនាំចូលផ្សេងពីវាក្យខណ្ឌ ក និងវាក្យខណ្ឌ ខ ដូចមានចែងក្នុងកថាខណ្ឌទី ១ នៃមាត្រានេះ ដែលបានផ្ទុកនៅលើមធ្យោបាយដឹកជញ្ជូនរាប់បញ្ចូលទាំងមធ្យោបាយដឹកជញ្ជូនយោធាដែលមកដល់កម្ពុជា ត្រូវរាយការណ៍ដោយជនទទួលខុសត្រូវមធ្យោបាយដឹកជញ្ជូនទាំងនោះ ។

ឃ- ក្នុងករណីទំនិញដែលនាំចូលតាមបែបផ្សេងទៀតត្រូវរាយការណ៍ដោយបុគ្គលដែលធ្វើក្នុងនាមអ្នកនាំចូល ។

បុគ្គលគ្រប់រូបដែលរាយការណ៍ពីទំនិញ ក្រោមបញ្ញត្តិនៃមាត្រានេះត្រូវ :

ក-ឆ្លើយនូវការពិត ចំពោះរាល់សំណួរដែលសួរដោយមន្ត្រីគយពាក់ព័ន្ធនឹងទំនិញរបស់ខ្លួន ។

ខ- បង្ហាញនូវទំនិញទាំងឡាយ តាមរបៀបដែលកំណត់ដោយនាយកទីចាត់ការគយ និងរដ្ឋាករសម្រាប់ធ្វើអធិការកិច្ចនៅពេលដែលមន្ត្រីគយតម្រូវ ។

**មាត្រា ១២.-**

គ្មានជនណាម្នាក់អាចរើទំនិញចេញពីមធ្យោបាយដឹកជញ្ជូនពេលមកដល់កម្ពុជាបានទេ មុនពេលដែលទំនិញទាំងនេះ ត្រូវបានរាយការណ៍ដល់គយស្របតាមច្បាប់នេះ លើកលែងតែក្នុងករណីដែលសុវត្ថិភាពមធ្យោបាយដឹកជញ្ជូនទំនិញ ជននានាលើមធ្យោបាយដឹកជញ្ជូន ឬ តតិយជនផ្សេងទៀតត្រូវបានគំរាមកំហែងក្នុងល័ក្ខខ័ណ្ឌមានអាសន្ន ដូចមានចែងក្នុងប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា ១៣.-**

រដ្ឋបាលគយអាចអនុញ្ញាតឱ្យទំនិញដូចមានចែងក្នុងមាត្រា ១០ នៃច្បាប់នេះយកចេញបានពីកន្លែងបំពេញបែបបទបញ្ចេញទំនិញពីគយ មុនពេលបង់ពន្ធ អាករ និងកម្រៃនានាបន្ទាប់ពីបានបំពេញទម្រង់ការគយរួច និងនៅក្រោមការត្រួតពិនិត្យគយក្នុងគោលបំណង :

-ធ្វើសន្និធិគយបណ្តោះអាសន្ន

-ធ្វើសន្និធិគយមានដែនកំណត់



ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL
ព្រះបរមរាជវាំង

12/45

-ដឹកជញ្ជូនបន្តក្នុងរង្វង់ ឬ កាត់តាមដែនគយ ឆ្លោះទៅគម្យដ្ឋានមួយតាមតម្រោយផ្លូវស្របច្បាប់ និងក្នុងរយៈពេលកំណត់ដោយគយរួមមាន ការឆ្លងកាត់ ការផ្ទេរមធ្យោបាយដឹកជញ្ជូន ឬ ការដឹកជញ្ជូនឆ្ពោះទៅកាន់មកពី ឬ រវាងការិយាល័យគយ និងភណ្ឌាគារគយនានា ។

## មាត្រា ១៤.-

ទំនិញដូចមានចែងក្នុងមាត្រា ១០ នៃច្បាប់នេះ អាចត្រូវបានអនុញ្ញាតដោយរដ្ឋបាលគយឱ្យយកចេញ បន្ទាប់ពីបានបំពេញទម្រង់ការគយរួច ដោយរាប់បញ្ចូលទាំងការបង់ពន្ធអាករ ឬ កម្រៃផ្សេងៗ និងការតម្កល់និមុត្តិធានាចំពោះទំនិញដើម្បី :

-នាំចូលសម្រាប់ការប្រើប្រាស់ក្នុងប្រទេស

-នាំចូលបណ្តោះអាសន្ន

-ប្រើប្រាស់ក្រោមល័ក្ខខ័ណ្ឌល្អូរពន្ធ ។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវចេញប្រកាសកំណត់ល័ក្ខខ័ណ្ឌនានាចំពោះទំនិញដែលអាចត្រូវបានអនុញ្ញាតឱ្យយកចេញ មុនពេលបង់ពន្ធ អាករ និងកម្រៃផ្សេងៗ ។

## មាត្រា ១៥.-

ទំនិញនាំចូលទាំងឡាយ អាចទទួលបានការអនុញ្ញាតដោយរដ្ឋបាលគយឱ្យយកចេញតាមរបបប្រវេសន៍កាលិកបាន ប្រសិនបើក្នុងពេលនាំចូលអាចត្រូវបានបង្ហាញថាទំនិញទាំងនោះនឹងត្រូវនាំចេញទៅវិញ ។

ទំនិញនាំចូលបណ្តោះអាសន្ន ត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យគយ រហូតដល់ពេលដែលល័ក្ខខ័ណ្ឌផ្សេងៗតាមរបបប្រវេសន៍កាលិកត្រូវបានបំពេញរួចរាល់ ។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចចេញប្រកាសកំណត់បញ្ញត្តិនានាសម្រាប់គ្រប់គ្រងទំនិញនាំចូលក្រោមរបបប្រវេសន៍កាលិកទាំងនេះ រួមមានការកំណត់រយៈពេលកម្រៃនានា ការត្រួតពិនិត្យ និងការដាក់កម្រិតកំណត់ផ្សេងទៀត ។

ROYAUME DU CAMBODGE LE MINISTÈRE DU PALAIS ROYAL ក្រសួងព្រះបរមរាជវាំង



13/45

## ផ្នែកទី ២

## ការនាំចេញ

**មាត្រា ១៦.–**

ទំនិញគ្រប់ប្រភេទដែលនាំចេញត្រូវរាយការណ៍នៅការិយាល័យគយ ឬ ទីកន្លែងណាមួយតាមការកំណត់របស់នាយកទីចាត់ការគយ និងរដ្ឋាករ ។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចចេញប្រកាសកំណត់ពេលវេលា របៀបរបប តម្រូវការ ឯកសារ កាលៈទេសៈ និងការលើកលែងមួយចំនួនពាក់ព័ន្ធនឹងការរាយការណ៍ ចរាចរ សន្និធិនិងការដឹកជញ្ជូនទំនិញទាំងឡាយដែលត្រូវនាំចេញ ។

បុគ្គលគ្រប់រូបដែលរាយការណ៍ពីទំនិញ ក្រោមបញ្ញត្តិនៃមាត្រានេះ ត្រូវ :

ក-ឆ្លើយនូវការពិតចំពោះរាល់សំណួរដែលសួរដោយមន្ត្រីគយ ពាក់ព័ន្ធនឹងទំនិញរបស់ខ្លួន ។

ខ-បង្ហាញនូវទំនិញទាំងឡាយ តាមរបៀបដែលកំណត់ដោយនាយកទីចាត់ការគយ និងរដ្ឋាករ សម្រាប់ធ្វើអធិការកិច្ចនៅពេលដែលមន្ត្រីគយតម្រូវ ។

**មាត្រា ១៧.–**

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចចេញប្រកាសកំណត់ល័ក្ខខ័ណ្ឌនានាដែលរដ្ឋបាលគយអាចអនុញ្ញាតឱ្យធ្វើការនាំចេញបណ្តោះអាសន្ននូវទំនិញទៅក្រៅដែនគយដើម្បីជួសជុល បំប្លែង ឬ ទទួលពលកម្មបន្ថែម ព្រមទាំងបែបបទដែលទំនិញទាំងនោះត្រូវជាប់ពន្ធ និងអាករនាពេលនាំចូលត្រឡប់មកវិញ ។

## ជំពូកទី ៣

## ចំណាត់ថ្នាក់តាមតារាង ដើមកំណើត និង តម្លៃគិតពន្ធគយ

**មាត្រា ១៨.–**

ចំណាត់ថ្នាក់តាមតារាង ដើមកំណើត និងតម្លៃគិតពន្ធគយនៃទំនិញនាំចូលដែលបានបញ្ជាក់នៅក្នុងប្រតិវេទន៍គយ ត្រូវបានប្រកាសស្របទៅតាមវិធានដូចខាងក្រោមនេះ :



ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

14/45

ក-ចំណាត់ថ្នាក់តាមតារាង និង ដើមកំណើត

-បុគ្គល អ្នកនាំចូល ឬ ភ្នាក់ងាររបស់ខ្លួនដែលបំពេញប្រតិវេទន៍គយនៃទំនិញនាំចូលត្រូវតែប្រកាសអំពីចំណាត់ថ្នាក់តាមតារាង និងដើមកំណើតនៃទំនិញទាំងនោះ ដើម្បីធ្វើការគណនាពន្ធ និងអាករ ។ រដ្ឋបាលគយត្រូវធ្វើការផ្ទៀងផ្ទាត់ចំណាត់ថ្នាក់តាមតារាង និងដើមកំណើតនៃទំនិញនាំចូល ។

- បុគ្គល អ្នកនាំចូល ឬភ្នាក់ងាររបស់ខ្លួន ដែលបំពេញប្រតិវេទន៍គយនៃទំនិញនាំចូលត្រូវតែធ្វើឡើងស្របតាមបញ្ញត្តិមាត្រា ៥១ និងមាត្រា ៥២ នៃច្បាប់នេះ ។

- រដ្ឋបាលគយអាចតម្រូវឱ្យបុគ្គល អ្នកនាំចូល ឬ ភ្នាក់ងាររបស់ខ្លួនបង្ហាញនូវសំអាងជាការប្រកាស ឬ ជាសំណុំឯកសារចាំបាច់ដែលតម្រូវដោយច្បាប់ និងបទប្បញ្ញត្តិជាធរមាន អំពីភាពត្រឹមត្រូវនៃប្រតិវេទន៍ ហើយអាចបដិសេធមិនបញ្ចេញទំនិញរហូតដល់ភស្តុតាងទាំងនេះត្រូវបានផ្តល់ជូន ។

-ក្នុងរយៈពេលបី (៣) ឆ្នាំ គិតពីថ្ងៃចុះបញ្ជិកាប្រតិវេទន៍គយ បន្ទាប់ពីការធ្វើសវនកម្ម ការស៊ើបអង្កេត អធិការកិច្ច ឬ ការត្រួតពិនិត្យឡើងវិញនូវទំនិញនាំចូល រដ្ឋបាលគយអាចកំណត់ឡើងវិញនូវចំណាត់ថ្នាក់តាមតារាង ឬ ដើមកំណើត ដែលបានប្រកាសដោយចេញនូវប្រវេសន៍ ។ ប្រវេសន៍នេះត្រូវមានចែងអំពីហេតុផលនៃការកំណត់ឡើងវិញនូវចំណាត់ថ្នាក់ តាមតារាង ឬ ដើមកំណើត ។

-នៅពេលដែលការធ្វើសវនកម្ម ការស៊ើបអង្កេត អធិការកិច្ច ឬ ការត្រួតពិនិត្យឡើងវិញ ត្រូវបានធ្វើឡើងនៅក្រោមមាត្រានេះ បានរកឃើញនូវសកម្មភាពខុសឆ្គងណាមួយនោះ ប្រវេសន៍អាចត្រូវបានចេញចំពោះតែទំនិញដែលស្ថិតនៅក្រោមការស៊ើបអង្កេត ក្នុងរយៈពេលមិនលើសពីដប់ (១០) ឆ្នាំ គិតពីថ្ងៃចុះបញ្ជិកាប្រតិវេទន៍គយ ។

- ពន្ធ និងអាករបន្ថែម កម្រៃផ្សេងទៀត និងការពិន័យទាំងអស់ ដែលជាប់ពីការចេញប្រវេសន៍នេះ ត្រូវតែបង់ជូនរដ្ឋបាលគយ ។

-រាល់ការបង្វិលសងវិញណាមួយនូវពន្ធ អាករ កម្រៃ និងការពិន័យដែលបានបង់លើស ដោយបុគ្គល អ្នកនាំចូល ឬ ភ្នាក់ងាររបស់ខ្លួន ដែលកើតឡើងពីការចេញប្រវេសន៍ត្រូវតែបង្វិលសងវិញដោយរដ្ឋបាលគយ ។



15/45

ខ-តម្លៃគិតពន្ធគយ

-បុគ្គល អ្នកនាំចូល ឬភ្នាក់ងាររបស់ខ្លួនដែលបំពេញប្រតិវេទន៍គយត្រូវតែប្រកាសអំពីតម្លៃគិតពន្ធគយនៃទំនិញនាំចូល ដូចដែលបានបញ្ញាក់នៅក្នុងបញ្ញត្តិមាត្រា ២១ នៃច្បាប់នេះ ដើម្បីធ្វើការវាយតម្លៃពន្ធ និងអាករ ។ រដ្ឋបាលគយត្រូវធ្វើការផ្ទៀងផ្ទាត់តម្លៃគិតពន្ធគយនៃទំនិញនាំចូលដែលបានប្រកាស ។

- បុគ្គល អ្នកនាំចូល ឬភ្នាក់ងាររបស់ខ្លួនដែលបំពេញប្រតិវេទន៍គយនៃទំនិញនាំចូលត្រូវតែធ្វើឡើងស្របតាមបញ្ញត្តិមាត្រា ៥១ និងមាត្រា ៥២ នៃច្បាប់នេះ ។

- បុគ្គល អ្នកនាំចូលឬ ភ្នាក់ងាររបស់ខ្លួនត្រូវទទួលខុសត្រូវក្នុងការប្រកាសឱ្យ បានត្រឹមត្រូវនូវតម្លៃគិតពន្ធគយ ដើម្បីបង់ប្រាក់ពន្ធ និងអាករ និង ត្រូវលាតត្រដាងរាល់ព័ត៌មានទាំងអស់ វិក្កយបត្រ និងឯកសារផ្សេងទៀត ដើម្បីឱ្យរដ្ឋបាលគយអាចផ្ទៀងផ្ទាត់ និងធ្វើការកំណត់ឱ្យ បានត្រឹមត្រូវនូវតម្លៃគិតពន្ធគយនៃទំនិញនាំចូល ។

-រដ្ឋបាលគយអាចតម្រូវឱ្យបុគ្គល អ្នកនាំចូល ឬ ភ្នាក់ងាររបស់ខ្លួនបង្ហាញនូវសំអាងជាការប្រកាស ឬជាសំណុំឯកសារចាំបាច់ដែលតម្រូវដោយច្បាប់ និងបទប្បញ្ញត្តិជាធរមាន អំពីភាពត្រឹមត្រូវនៃប្រតិវេទន៍ ហើយអាចបដិសេធមិនបញ្ចេញទំនិញរហូតដល់ភស្តុតាងទាំងនេះត្រូវបានផ្តល់ជូន ។

-ក្នុងរយៈពេល បី (៣) ឆ្នាំ គិតពីថ្ងៃចុះបញ្ជិកាប្រតិវេទន៍គយ បន្ទាប់ពីការធ្វើសវនកម្ម ការស៊ើបអង្កេត អធិការកិច្ច ឬ ការត្រួតពិនិត្យឡើងវិញនូវទំនិញនាំចូល រដ្ឋបាលគយអាចកំណត់ឡើងវិញនូវតម្លៃគិតពន្ធគយ ដែលបានប្រកាសដោយចេញនូវប្រវេសន៍ ។ ប្រវេសន៍នេះត្រូវមានចែងអំពីហេតុផលនៃការកំណត់ឡើងវិញនូវតម្លៃគិតពន្ធគយ ។

- រដ្ឋបាលគយអាចកែប្រែតម្លៃគិតពន្ធគយដែលបានប្រកាស ប្រសិនបើតម្លៃគិតពន្ធគយដែលបានប្រកាស មិនស្របទៅតាមបញ្ញត្តិមាត្រា ២១ នៃច្បាប់នេះ ឬ មិនត្រឹមត្រូវដោយហេតុផលផ្សេងទៀត ។

-នៅពេលដែលការធ្វើសវនកម្ម ការស៊ើបអង្កេត អធិការកិច្ច ឬ ការត្រួតពិនិត្យឡើងវិញត្រូវបានធ្វើឡើងនៅក្រោមមាត្រានេះ បានរកឃើញនូវសកម្មភាពខុសឆ្គងណាមួយនោះ ប្រវេសន៍អាចត្រូវបានចេញចំពោះតែទំនិញដែលស្ថិតនៅក្រោមការស៊ើបអង្កេតក្នុង

រយៈពេលមិនលើសពីដប់ (១០) ឆ្នាំ គិតពីថ្ងៃចុះបញ្ជិកាប្រតិវេទន៍គយ ។

គ-ការប្រកាសដោយស្ម័គ្រចិត្តអំពីពន្ធ អាករ ឬ កម្រៃផ្សេងៗបន្ថែម ដែលត្រូវបង់

បុគ្គល អ្នកនាំចូល ឬ ភ្នាក់ងាររបស់ខ្លួន អាចធ្វើការប្រកាសដោយស្ម័គ្រចិត្ត ជូនរដ្ឋបាលគយអំពីពន្ធ អាករ ឬ កម្រៃផ្សេងៗ ដែលពុំទាន់បានបង់លើទំនិញនាំចូលដោយពុំទទួលរងនូវការពិន័យ ឬទោសទណ្ឌនានាឡើយ ប្រសិនបើការប្រកាសនេះត្រូវបានធ្វើជូនរដ្ឋបាលគយក្នុងរង្វង់មួយ (១) ឆ្នាំ គិតចាប់ពីថ្ងៃចុះបញ្ជិកាប្រតិវេទន៍គយ ។

ឃ-អ្នកនាំចេញ និង ទំនិញនាំចេញ

បញ្ញត្តិនៃកថាខណ្ឌ ក និងកថាខណ្ឌ គ នៃមាត្រានេះត្រូវអនុវត្តផងដែរចំពោះទំនិញនាំចេញ ។

## មាត្រា ១៩.-

សម្រាប់គោលបំណងនៃការនាំចេញ និងនាំចូល ទំនិញទាំងឡាយត្រូវបានធ្វើចំណាត់ថ្នាក់ ហើយពន្ធ និងអាករ ត្រូវបានគណនាស្របតាមតារាងពន្ធគយ វៀរលែងតែត្រូវបានលើកលែងដោយច្បាប់នេះ ឬ ច្បាប់ផ្សេងទៀតជាធរមាននៃព្រះរាជាណាចក្រកម្ពុជា ។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវចេញប្រកាសកំណត់នូវបញ្ញត្តិពាក់ព័ន្ធនឹងការធ្វើចំណាត់ថ្នាក់តាមតារាង ។

## មាត្រា ២០.-

សម្រាប់ការនាំចូល ការប្រមូលពន្ធ និងអាករនានា ត្រូវអនុវត្តស្របតាមដើមកំណើតនៃទំនិញ ។

ដើមកំណើតនៃផលិតផលធម្មជាតិនានា គឺជាប្រទេសដែលផលិតផលនោះត្រូវបានប្រមូល ឬ ទាញយកពីដី ។

ទំនិញឧស្សាហផលដែលបានផលិតនៅក្នុងប្រទេសតែមួយ ដោយពុំមានការដាក់បញ្ចូលវត្ថុធាតុដើមពីប្រទេសដទៃ គឺមានដើមកំណើតពីប្រទេសដែលឧស្សាហផលនោះត្រូវបានផលិត ។

បែបបទដែលរដ្ឋបាលគយត្រូវអនុវត្ត ដើម្បីផ្ទៀងផ្ទាត់ដើមកំណើតទំនិញ ដែលបានផលិតនៅក្នុងប្រទេសមួយ ដោយប្រើប្រាស់ផលិតផលដែលបានមកពីការប្រមូល ឬ ទាញ



17/45

យកពីដី ឬ ផលិតនៅប្រទេសផ្សេងទៀត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ទំនិញនាំចូលទាំងឡាយនឹងទទួលសេចក្តីអនុគ្រោះចំពោះដើមកំណើតបាន លុះត្រាតែមានការជូនសំអាងដោយត្រឹមត្រូវអំពីដើមកំណើត និងការដឹកជញ្ជូនត្រង់ពីប្រទេសដើមកំណើតទៅប្រទេសនាំចូល ។ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចចេញប្រកាសកំណត់ល័ក្ខខ័ណ្ឌដែលតម្រូវ និង មិនតម្រូវឱ្យជូនសំអាង ។

ប្រទេសនាំចេញគឺជាប្រទេសដែលទំនិញត្រូវបានគេបញ្ជូនដោយត្រង់សំដៅមកដែនគយ ។

## មាត្រា ២១.-

តម្លៃគិតពន្ធគយលើទំនិញនាំចូល ត្រូវបានកំណត់ទៅតាមវិធានដូចខាងក្រោមនេះ :

ក- តម្លៃគិតពន្ធគយលើទំនិញនាំចូល គឺជាតម្លៃចម្លងការ មានន័យថាថ្លៃដែលបានទូទាត់ ឬ នឹងត្រូវទូទាត់ពិតប្រាកដ លើទំនិញដែលបានលក់សម្រាប់នាំចេញមកព្រះរាជាណាចក្រកម្ពុជា ស្របតាមបញ្ញត្តិនៃប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដូចមានកំណត់ក្នុងវាក្យខណ្ឌ ជ នៃមាត្រានេះ ។

ខ- ប្រសិនបើតម្លៃគិតពន្ធគយនៃទំនិញនាំចូលពុំអាចត្រូវបានកំណត់ក្រោមបញ្ញត្តិនៃវាក្យខណ្ឌ ក នៃមាត្រានេះ តម្លៃគិតពន្ធគយគឺជាតម្លៃចម្លងការនៃទំនិញដូចគ្នា ។

គ- ប្រសិនបើតម្លៃគិតពន្ធគយនៃទំនិញនាំចូលពុំអាចត្រូវបានកំណត់ក្រោមបញ្ញត្តិនៃវាក្យខណ្ឌ ក និងវាក្យខណ្ឌ ខ នៃមាត្រានេះ តម្លៃគិតពន្ធគយ គឺជាតម្លៃចម្លងការនៃទំនិញប្រហាក់ប្រហែលគ្នា ។

ឃ-ប្រសិនបើតម្លៃគិតពន្ធគយនៃទំនិញនាំចូលពុំអាចត្រូវបានកំណត់ក្រោមបញ្ញត្តិនៃវាក្យខណ្ឌ ក វាក្យខណ្ឌ ខ និងវាក្យខណ្ឌ គ នៃមាត្រានេះ តម្លៃគិតពន្ធគយត្រូវផ្អែកលើវិធីសាស្ត្រអនុមាន ។

ង- ប្រសិនបើតម្លៃគិតពន្ធគយនៃទំនិញនាំចូលពុំអាចត្រូវបានកំណត់ក្រោមបញ្ញត្តិនៃវាក្យខណ្ឌ ក វាក្យខណ្ឌ ខ វាក្យខណ្ឌ គ និងវាក្យខណ្ឌ ឃ នៃមាត្រានេះ តម្លៃគិតពន្ធគយត្រូវផ្អែកលើវិធីសាស្ត្រគណនា ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
ក្រសួងព្រះបរមរាជវាំង



18/45

ច- លំដាប់នៃការអនុវត្តនៃវាក្យខណ្ឌ ឃ និងវាក្យខណ្ឌ ង នៃមាត្រានេះអាចត្រូវត្រឡប់ចុះឡើងបានតាមសំណើរបស់អ្នកនាំចូល ។

ឆ- ប្រសិនបើតម្លៃគិតពន្ធគយនៃទំនិញនាំចូលពុំអាចត្រូវបានកំណត់ក្រោមបញ្ញត្តិនៃវាក្យខណ្ឌ ក វាក្យខណ្ឌ ខ វាក្យខណ្ឌ គ វាក្យខណ្ឌ ឃ និងវាក្យខណ្ឌ ង នៃមាត្រានេះ តម្លៃគិតពន្ធគយត្រូវកំណត់ដោយប្រើប្រាស់មធ្យោបាយសមស្របនានាដែលស៊ីចង្វាក់ទៅនឹងគោលការណ៍ និងបញ្ញត្តិនានានៃវាក្យខណ្ឌ ក វាក្យខណ្ឌ ខ វាក្យខណ្ឌ គ វាក្យខណ្ឌ ឃ និង វាក្យខណ្ឌ ង នៃមាត្រានេះ ដោយផ្អែកលើមូលដ្ឋានទិន្នន័យដែលមានស្រាប់នៅក្នុងដែនគយក្រោមល័ក្ខខ័ណ្ឌច្បាស់លាស់ ។

ជ-រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬ រដ្ឋមន្ត្រីទទួលបន្ទុកហិរញ្ញវត្ថុ ត្រូវចេញប្រកាសកំណត់នូវរាល់បញ្ហាដែលពាក់ព័ន្ធនឹងការកំណត់តម្លៃគិតពន្ធគយ ។

**មាត្រា ២២.-**

តម្លៃគិតពន្ធគយនៃទំនិញនាំចេញ គឺជាតម្លៃទំនិញនៅចំណុចនាំចេញ ។

តម្លៃគិតពន្ធគយនេះនឹងត្រូវកំណត់ដោយត្រូវបូកថ្លៃដឹកជញ្ជូនទំនិញរួមទាំងរាល់ចំណាយទាំងឡាយ ដែលត្រូវបង់សម្រាប់ប្រតិបត្តិការនាំចេញរហូតដល់ព្រំដែន លើកលែងអាករនាំចេញ អាករក្នុងប្រទេស និងបន្ទុកប្រហាក់ប្រហែលដែលអ្នកនាំចេញបានបង់និងមានបង្កាន់ដៃ ។

**មាត្រា ២៣.-**

តម្លៃគិតពន្ធគយនៃទំនិញនាំចូល និងទំនិញនាំចេញត្រូវប្រកាសជាប្រាក់រៀល ។

ប្រសិនបើតម្លៃគិតពន្ធគយ ត្រូវបានបង្ហាញជារូបិយវត្ថុផ្សេងពីរូបិយវត្ថុកម្ពុជា អត្រាប្តូរប្រាក់ដែលត្រូវអនុវត្ត គឺជាអត្រាដែលកំណត់ដោយធនាគារជាតិនៃកម្ពុជា ។ ប៉ុន្តែចំពោះអត្រាប្តូរប្រាក់ដែលមិនមានកំណត់ក្នុងតារាងអត្រាប្តូរប្រាក់របស់ធនាគារជាតិនៃកម្ពុជា រដ្ឋបាលគយអាចកំណត់បាន ។

អត្រាប្តូរប្រាក់ដែលត្រូវអនុវត្ត គឺជាអត្រាប្តូរប្រាក់ដែលប្រើនៅក្នុងថ្ងៃចុះបញ្ជិកាប្រតិវេទន៍គយ ។

អត្រាប្តូរប្រាក់ត្រូវផ្សព្វផ្សាយជាសាធារណៈដោយរដ្ឋបាលគយ ។



19/45

**មាត្រា ២៤.-**

បុគ្គល អ្នកនាំចូល ឬ ភ្នាក់ងាររបស់ខ្លួនដែលមិនពេញចិត្តចំពោះហេតុផល ឬ ភាពត្រឹមត្រូវនៃការកំណត់ឡើងវិញនូវចំណាត់ថ្នាក់តាមតារាង ដើមកំណើត ឬ តម្លៃគិតពន្ធគយដែលបានផ្តល់ជូនក្នុងប្រវេសន៍ ដូចមានចែងក្នុងបញ្ញត្តិនៃកថាខណ្ឌ ក និងកថាខណ្ឌ ខ មាត្រា ១៨ នៃច្បាប់នេះ អាចជំទាស់ទៅនឹងការសម្រេចនេះជាលាយលក្ខណ៍អក្សរទៅនាយកទីចាត់ការគយនិងរដ្ឋាករ ក្នុងរយៈពេលសាមសិប (៣០) ថ្ងៃ គិតពីថ្ងៃដែលប្រតិវេទករបានទទួលប្រវេសន៍ពីការកំណត់ឡើងវិញនូវចំណាត់ថ្នាក់តាមតារាង ដើមកំណើត ឬ តម្លៃគិតពន្ធគយនេះ ។

នៅក្នុងករណីដែលតម្លៃគិតពន្ធគយ គឺជាកម្មវត្ថុនៃការតវ៉ា ទំនិញត្រូវបានអនុញ្ញាតឱ្យយកចេញពីគយដោយគ្មានការបង់ប្រាក់ពន្ធ និងអាករឡើយ ប្រសិនបើអ្នកនាំចូលតម្កល់នូវនិមុត្តិធានាគ្រប់គ្រាន់ ដើម្បីធានាប្រាក់ពន្ធ និង អាករ ។

នាយកទីចាត់ការគយ និងរដ្ឋាករ ត្រូវធ្វើសេចក្តីសម្រេចលើការជំទាស់ដូចមានចែងក្នុងកថាខណ្ឌទី ១ នៃមាត្រានេះ ក្នុងរយៈពេលហុកសិប (៦០) ថ្ងៃ បន្ទាប់ពីការជំទាស់ត្រូវបានទទួល ។ បើមិនដូច្នោះទេ ការជំទាស់នឹងត្រូវចាត់ទុកថា បានយល់ព្រម ហើយនិមុត្តិធានាត្រូវប្រគល់ជូនវិញ ។

បុគ្គលណា ដែលជំទាស់ទៅនឹងការសម្រេចរបស់នាយកទីចាត់ការគយ និងរដ្ឋាករ ដូចមានចែងក្នុងកថាខណ្ឌទី ១ នៃមាត្រានេះ អាចធ្វើការតវ៉ាជាលាយលក្ខណ៍អក្សរទៅគណៈកម្មាធិការតារាងពន្ធគយបាន ។

ការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការតារាងពន្ធគយ ត្រូវកំណត់ដោយអនុក្រឹត្យ ។

អ្នកនាំចេញ ឬ អ្នកនាំចូល មានសិទ្ធិធ្វើការតវ៉ាទៅតុលាការមានសមត្ថកិច្ច ជំទាស់នឹងការសម្រេចរបស់គណៈកម្មាធិការតារាងពន្ធគយក្នុងរយៈពេលសាមសិប (៣០) ថ្ងៃ គិតពីថ្ងៃបានទទួលនូវសេចក្តីជូនដំណឹងពីការសម្រេចនេះ ។



20/45

# ជំពូកទី ៤
# ការលើកលែង ការលើកលែងជាភាគ និង
# ការបង្វិលសងវិញនូវពន្ធ និងអាករ

**មាត្រា ២៥.–**

ទំនិញដែលចូលក្នុងដែនគយសម្រាប់ឆ្លងកាត់ ឬ ផ្ទេរមធ្យោបាយដឹកជញ្ជូន មិនត្រូវជាប់ពន្ធ និងអាករនាំចូលឡើយ ។

**មាត្រា ២៦.–**

ការលើកលែងពន្ធនិងអាករនាំចូលត្រូវអនុញ្ញាតផ្តល់ជូនចំពោះការនាំចូល :

ក- ទំនិញសម្រាប់បេសកកម្មការទូត ឬបេសកកម្មកុងស៊ុលបរទេស អង្គការអន្តរជាតិ និងភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលផ្សេងទៀត ដើម្បីប្រើប្រាស់ក្នុងការិយកិច្ចនៃមុខងារជាផ្លូវការ ដោយមានការបញ្ជាក់ពីប្រធានបេសកកម្ម និងពីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ។

ខ-ទំនិញសម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួនរបស់បុគ្គលិកផ្លូវការនៃបេសកកម្ម និងអង្គ-ការ ដូចបានរៀបរាប់នៅក្នុងវាក្យខណ្ឌ ក កថាខណ្ឌទី ១ នៃមាត្រានេះ ។ ការអនុវត្តនូវវាក្យខណ្ឌនេះ និងវាក្យខណ្ឌ ក កថាខណ្ឌទី ១ នៃមាត្រានេះ ត្រូវផ្អែកលើគោលការណ៍ច្បាប់អន្តរជាតិ និងគោលការណ៍បដិការរវាងរដ្ឋាភិបាលពាក់ព័ន្ធ ។

គ-ទំនិញមានដើមកំណើតកម្ពុជា ឬទំនិញនាំចូលដែលបានបង់ពន្ធ និងអាកររួច ដែលចេញពីដែនគយហើយត្រូវនាំចូលត្រឡប់ពីបរទេសមកវិញ ដោយពុំមានការបង្កើនតម្លៃ ។

ឃ- ទំនិញដែលត្រូវលើកលែងពន្ធ និងអាករក្រោមបញ្ញត្តិនៃច្បាប់ផ្សេងទៀតរបស់ព្រះរាជាណាចក្រកម្ពុជា ។

ង- ទំនិញជាអំណោយសម្រាប់មនុស្សធម៌ ទំនិញសម្រាប់ការស្រាវជ្រាវ និងគោលបំណងវិទ្យាសាស្ត្រ ទំនិញគំរូ និងទំនិញតាំងពិព័រណ៍ដែលគ្មានតម្លៃពាណិជ្ជកម្ម



21/45

មឈូសដែលមានសាកសពមនុស្ស និងទំនិញផ្សេងទៀត ដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ទំនិញនាំចូលដែលត្រូវលើកលែងពន្ធ និងអាករក្រោមបញ្ញត្តិកថាខណ្ឌទី ១ នៃមាត្រានេះ មិនអាចត្រូវបានលក់ ផ្ទេរ បង្វែរទៅប្រើប្រាស់អ្វីផ្សេង ឬ បោះបង់ចោលដោយគ្មានការអនុញ្ញាតជាមុនពីរដ្ឋបាលគយឡើយ ។

ទំនិញដែលមានតម្លៃ និងបរិមាណច្បាស់លាស់មួយចំនួន កំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលនាំចូលដោយអ្នកដំណើរ អ្នកបម្រើការតាមមធ្យោបាយដឹកជញ្ជូន និងជនទាំងឡាយដែលឆ្លងកាត់ព្រំដែនត្រូវលើកលែងពន្ធ និងអាករនាំចូល ។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចចេញប្រកាសកំណត់បាននូវបញ្ញត្តិនានាដែលពាក់ព័ន្ធចំពោះទំនិញដូចមានចែងក្នុងវាក្យខណ្ឌ ក វាក្យខណ្ឌ ខ វាក្យខណ្ឌ គ វាក្យខណ្ឌ ឃ និងវាក្យខណ្ឌ ង ក្នុងកថាខណ្ឌទី ១ នៃមាត្រានេះ ដោយរួមទាំងការលក់ ការផ្ទេរ ការបង្វែរ និងការបោះបង់ចោល ក្រោមបញ្ញត្តិកថាខណ្ឌទី ២ នៃមាត្រានេះ ។

**មាត្រា ២៧.–**

ការលើកលែងជាភាគនៃពន្ធ និងអាករនាំចូល អាចនឹងផ្តល់ជូនបានចំពោះការនាំចូល :

ក-ទំនិញ និងសម្ភារៈដែលមានចែងដោយច្បាប់ផ្សេងទៀតរបស់ព្រះរាជាណាចក្រកម្ពុជា ។

ខ-ពូជដំណាំ និងពូជសត្វសម្រាប់កសិកម្ម ទំនិញដែលនឹងត្រូវទទួលការជួសជុល ការកែច្នៃ ឬ ពិសោធន៍ ទំនិញដែលបាននាំចូលវិញតាមសភាពដើម ទំនិញដែលនាំចូលដោយរដ្ឋាភិបាលដើម្បីជាប្រយោជន៍សាធារណៈ ទំនិញនាំចូលសម្រាប់របបប្រវេសន៍កាលិក និងទំនិញផ្សេងទៀតដែលបានកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ទំនិញដែលនាំចូលក្រោមបញ្ញត្តិនៃមាត្រានេះ មិនអាចត្រូវបានលក់ ផ្ទេរ បង្វែរ ឬ បោះបង់ចោលដោយគ្មានការអនុញ្ញាតជាមុនពីរដ្ឋបាលគយបានឡើយ ។



ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL
22/45

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចចេញប្រកាសកំណត់នូវបញ្ញត្តិនានាដែលពាក់ព័ន្ធចំពោះទំនិញដូចមានចែងក្នុងកថាខណ្ឌទី ១ នៃមាត្រា នេះរួមទាំងការលក់ ការផ្ទេរ ការបង្វែរ និងការបោះបង់ចោលក្រោមបញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រានេះផង ។

**មាត្រា ២៨.-**

រដ្ឋបាលគយអាចផ្តល់បាននូវការបង្វិលសងវិញទាំងស្រុង ឬ ភាគខ្លះនូវពន្ធ និងអាករនាំចូលដែលបានបង់រួចចំពោះ :

ក- ការបង់លើសដោយប្រការណាមួយ រាប់បញ្ចូលទាំងករណីដែលបណ្តាលមកពីការភ័ន្តច្រឡំរដ្ឋបាលផង ។

ខ-ទំនិញនាំចូលដែលនៅមុនពេលអនុញ្ញាតឱ្យយកចេញពីគយត្រូវពិនិត្យឃើញថា តិចជាង បែកបាក់ខូចខាត គុណភាពទាប និងទំនិញនាំចេញទៅវិញ ឬ បំផ្លាញចោល ក្រោមការគ្រប់គ្រង ឃ្លាំមើលរបស់គយ ទោះបីនៅក្រោយពេលអនុញ្ញាតឱ្យយកចេញពីគយរួចហើយក៏ដោយ ។

គ-ការបង់លើសដែលបានរកឃើញតាមរយៈសេចក្តីសម្រេចរបស់អាជ្ញាធរទទួលបន្ទុកដោះស្រាយការតវ៉ាដូចមានចែងក្នុងមាត្រា ២៤ នៃច្បាប់នេះ ឬ ដោយតុលាការមានសមត្ថកិច្ច ។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវចេញប្រកាសស្តីពីការបង្វិលសងវិញដែលបានរៀបរាប់ខាងលើ និងការបង្វិលសងវិញ ដោយមូលហេតុផ្សេងទៀតរួមទាំងការកម្រិតពេលវេលាផងដែរ ។

## ជំពូកទី ៥

## ប្រតិវេទន៍គយ និងការទទួលខុសត្រូវចំពោះពន្ធ និងអាករ

**មាត្រា ២៩.-**

រាល់ទំនិញនាំចេញ ឬ នាំចូល ទោះជាជាប់ពន្ធ និងអាករក្តី ឬ ត្រូវបានលើកលែងពន្ធ និងអាករ ទំនិញទាំងនោះត្រូវតែជាកម្មវត្ថុនៃការធ្វើប្រតិវេទន៍គយ ។

**មាត្រា ៣០.-**

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវចេញប្រកាសពាក់ព័ន្ធនឹង :

-ទម្រង់ ខ្លឹមសារ និងសុពលភាពនៃប្រតិវេទន៍ និងឯកសារគយ

-ការតម្កល់ ការផ្ទៀងផ្ទាត់ និង ការចុះបញ្ជិកាប្រតិវេទន៍គយ

-ការកែប្រែ ការបន្ថែម និងការលុប ឬ ប្តូរនូវប្រតិវេទន៍ និង ឯកសារគយ

-ការបែងចែក និងគ្រប់គ្រងត្រួតពិនិត្យ ប្រតិវេទន៍ និងឯកសារគយ ។

**មាត្រា ៣១.-**

ទំនិញនាំចេញ ឬ នាំចូលត្រូវប្រកាសដោយម្ចាស់ទំនិញ ឬ ដោយបុគ្គលដែលបានទទួលការអនុញ្ញាតឱ្យបំពេញបែបបទគយក្នុងនាមម្ចាស់ទំនិញ ។

**មាត្រា ៣២.-**

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុអាចចេញប្រកាសផ្តល់ ឬដកមកវិញនូវការអនុញ្ញាតបាន ចំពោះបុគ្គលណាមួយជាជើងសាគយ និងកំណត់នូវទីតាំងដែលការអនុញ្ញាតនោះមានសុពលភាព និងល័ក្ខខ័ណ្ឌ ឬ លក្ខណៈសម្បត្តិនានាសម្រាប់ការអនុញ្ញាតនេះ ។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចបង្កើតគណៈកម្មាធិការមួយបានសម្រាប់ផ្តល់យោបល់លើការអនុញ្ញាតនេះ និងរាល់បញ្ហាទាំងឡាយដែលពាក់ព័ន្ធនឹងជើងសាគយ ។

ការអនុញ្ញាតជាជើងសាគយ ត្រូវបានផ្តល់សម្រាប់ជនម្នាក់ៗ ។ ប្រសិនបើជាការស្នើសុំរបស់នីតិបុគ្គល ការអនុញ្ញាតនឹងត្រូវផ្តល់ជូននីតិបុគ្គលនោះ និងជនដែលទទួលសិទ្ធិជាតំណាង ។

ការបដិសេធ ការដកមកវិញនូវការអនុញ្ញាតជាបណ្តោះអាសន្ន ឬ ជាអចិន្ត្រៃយ៍ជាជើងសាគយពុំត្រូវបានផ្តល់នូវសំណង ឬ ជម្ងឺចិត្តអ្វីឡើយ ។

ជើងសាគយដែលបានអនុញ្ញាត អាចត្រូវតម្កល់និមុត្តិធានាពាក់ព័ន្ធនឹងប្រតិបត្តិ-ការរបស់ខ្លួនតាមទម្រង់ និងចំនួនទឹកប្រាក់ដូចដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា ៣៣.-**

បុគ្គលណាដែលគ្មានវិជ្ជាជីវៈជាជើងសាគយ អាចបំពេញប្រតិវេទន៍គយបានសម្រាប់



ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *
24/45

អាជីវកម្មខ្លួន ។

បុគ្គលដែលមានចែងក្នុងកថាខណ្ឌទី ១ នៃមាត្រានេះអាចទទួលបានការអនុញ្ញាតឱ្យបញ្ចេញទំនិញពីគយសម្រាប់អ្នកដទៃ ។ ការអនុញ្ញាតនេះត្រូវបានផ្តល់ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាបណ្តោះអាសន្ន ហើយអាចដកហូតវិញបានសម្រាប់ប្រតិបត្តិការពាក់ព័ន្ធនឹងទំនិញដោយឡែកមួយចំនួន ។

**មាត្រា ៣៤.–**

ពន្ធ និងអាករនាំចូលត្រូវគណនាដោយផ្អែកលើមូលដ្ឋានអត្រាពន្ធ ឬ អាករ ជាធរមាននៅថ្ងៃចុះបញ្ជិកាប្រតិវេទន៍គយ ។

ពន្ធ និងអាករនាំចូលត្រូវគណនាដោយផ្អែកលើមូលដ្ឋាន ពន្ធគិតតាមតម្លៃ ឬ ពន្ធគិតតាមឯកតា ។

**មាត្រា ៣៥.–**

អ្នកនាំចូល ឬ ម្ចាស់ទំនិញត្រូវទទួលខុសត្រូវចំពោះពន្ធ និងអាករនាំចូល ។

ក្នុងករណីដែលអ្នកនាំចូល ឬ ម្ចាស់ទំនិញមិនត្រូវបានរកឃើញ ភ្នាក់ងារជើងសាគយត្រូវទទួលខុសត្រូវចំពោះពន្ធ និងអាករនាំចូល ។

ក្នុងករណីសន្និធិគយបណ្តោះអាសន្ន ឬ សន្និធិគយមានដែនកំណត់ ប្រតិបត្តិករនៃសន្និធិទាំងនេះ ជាអ្នកទទួលខុសត្រូវចំពោះពន្ធ អាករ និងកម្រៃផ្សេងៗដោយមិនទាន់គិតដល់ទោសទណ្ឌផ្សេងទៀតដែលអាចត្រូវទទួល រហូតដល់ទំនិញត្រូវបាននាំចេញទៅវិញនាំចូលបណ្តោះអាសន្ន នាំចូលដើម្បីប្រើប្រាស់ក្នុងប្រទេស បង្វែរទៅទីកន្លែងសន្និធិផ្សេងទៀត ឬ បំផ្លាញចោលដោយមានការអនុញ្ញាតពីរដ្ឋបាលគយ ។

នៅក្នុងករណីមាត្រា ២៦ និងមាត្រា ២៧ នៃច្បាប់នេះ ប្រសិនបើល័ក្ខខ័ណ្ឌនៃការលើកលែងពន្ធ និងអាករនាំចូលមិនត្រូវបានបំពេញសព្វគ្រប់ ការទទួលខុសត្រូវចំពោះពន្ធ និងអាករនាំចូលជាបន្ទុករបស់បុគ្គលដែលបានទទួលការលើកលែងពន្ធ និងអាករនាំចូល ប្រសិនជាមិនអាចរកឃើញបុគ្គលនោះ បន្ទុកនេះត្រូវធ្លាក់ទៅលើបុគ្គលដែលកាន់កាប់ទំនិញនោះ ។

ជនណាដែលជាអ្នកកាន់កាប់ទំនិញនាំចូលនាពេលដែលមធ្យោបាយដឹកជញ្ជូនចូល



ROYAUME du CAMBODGE · LE MINISTRE du PALAIS ROYAL

25/45

ក្នុងដែនគយ រាប់បញ្ចូលទាំងប្រតិបត្តិករមធ្យោបាយដឹកជញ្ជូនផង ជននោះជាអ្នកទទួលខុសត្រូវលើពន្ធ និងអាករនាំចូលនៃទំនិញនោះ ។

**មាត្រា ៣៦.-**

អ្នកនាំចេញ ឬម្ចាស់ទំនិញត្រូវទទួលខុសត្រូវចំពោះពន្ធ និងអាករនាំចេញ ។

ក្នុងករណីដែលអ្នកនាំចេញ ឬ ម្ចាស់ទំនិញមិនអាចត្រូវបានរកឃើញជើងសាគយត្រូវទទួលខុសត្រូវចំពោះពន្ធ និងអាករនាំចេញ ។

ក្នុងករណីសន្និធិគយណ្ដោះអាសន្ន និងសន្និធិគយមានដែនកំណត់ ប្រតិបត្តិករនៃសន្និធិទាំងនេះត្រូវទទួលខុសត្រូវចំពោះពន្ធ និងអាករនាំចេញ ។

## ជំពូកទី ៦

## ការបង់ប្រាក់ពន្ធ និងអាករនាំចូល និងនាំចេញ

## ការប្រមូលបំណុល និងនិមុត្តិធានា

**មាត្រា ៣៧.-**

ពន្ធ និងអាករនាំចេញ និងនាំចូល ព្រមទាំងកម្រៃមានការអនុញ្ញាត ការពិន័យ ការប្រាក់ ឬ ទោសទណ្ឌដែលត្រូវជាប់ក្រោមច្បាប់នេះ និងច្បាប់ផ្សេងទៀតនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបង់នៅកន្លែង តាមរបៀប និង ពេលវេលាកំណត់ ដូចមានចែងក្នុងប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

ពន្ធ និងអាករដែលត្រូវបង់សម្រាប់មុខទំនិញនីមួយៗក្នុងប្រតិវេទន៍គយតែមួយត្រូវគិតជាប្រាក់រៀលដោយដំឡើងដល់ខ្ទង់រយជិតបំផុត ។

បង្កាន់ដៃត្រូវបានផ្ដល់សម្រាប់រាល់ការចំណាយដែលបានបង់ ។

**មាត្រា ៣៨.-**

បំណុលដែលជំពាក់ស្របតាមបញ្ញត្តិនៃច្បាប់នេះហើយពុំបានបង់ទាំងស្រុង ឬភាគខ្លះ តាមពេលវេលាកំណត់ ត្រូវជាប់ការប្រាក់គរពូន ទៅតាមអត្រាដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា ៣៩.–**

រដ្ឋបាលគយមានបុព្វសិទ្ធិខាងទាមទារយកទំនិញ និងទ្រព្យសម្បត្តិរបស់ឥណាយិក ដែលជំពាក់ស្របតាមបញ្ញត្តិនៃច្បាប់នេះ ។

**មាត្រា ៤០.–**

នីតិវិធីនៃការប្រមូល និងការលុបចោលនូវបំណុល ដែលមិនអាចប្រមូលបានត្រូវផ្អែកលើបញ្ញត្តិ និងច្បាប់នានាជាធរមាន ។

**មាត្រា ៤១.–**

និមុត្តិធានាដែលតម្រូវដោយច្បាប់នេះ អាចត្រូវប្រើប្រាស់ម្តង ឬ ច្រើនដងដែលអាចមានទម្រង់ជាសាច់ប្រាក់ ការធានា ឬ ជាលិខិតុបករណ៍ផ្សេងទៀតបាន ។ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុអាចចេញប្រកាសកំណត់បាននូវបញ្ញត្តិដែលពាក់ព័ន្ធនឹងនិមុត្តិធានានេះ ។

**មាត្រា ៤២.–**

នាយកទីចាត់ការគយនិងរដ្ឋាករអាចដោះបន្ទុកនិមុត្តិធានាដែលបានតម្កល់សម្រាប់ធានាលើការនាំចេញ ឬការនាំចេញបន្តនូវទំនិញខ្លះ ក្រោយពីមានការជូនសំអាងដែលកំណត់ថា ទំនិញទាំងនេះពិតជាបាននាំចេញ ឬ នាំចេញបន្តទៅវិញមែន ។

## ជំពូកទី ៧

## សន្និធិគយបណ្តោះអាសន្ន និងតណ្ឋាគារគយមានដែនកំណត់

**មាត្រា ៤៣.–**

សន្និធិគយបណ្តោះអាសន្ន គឺសំដៅលើសន្និធិទំនិញ ដែលស្ថិតក្រោមការត្រួតពិនិត្យគយ នៅទីកន្លែងដែលបានទទួលការអនុញ្ញាត ដើម្បីរង់ចាំការបំពេញបែបបទបញ្ចេញទំនិញពីគយ ។

អាជ្ញាប័ណ្ណសម្រាប់ប្រតិបត្តិការទីកន្លែងសន្និធិគយបណ្តោះអាសន្ន ត្រូវសម្រេចដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ អាជ្ញាប័ណ្ណនេះ កំណត់នូវល័ក្ខខ័ណ្ឌសម្រាប់ម្ចាស់

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL



27/45

កម្មសិទ្ធិ និងប្រតិបត្តិកររាប់បញ្ចូលទាំងទីតាំង សំណង់ គម្រោងអគារ នីតិវិធីសម្រាប់ចាត់ចែង និងគ្រប់គ្រង ។

ចំណាយពាក់ព័ន្ធនឹងទីកន្លែងសន្និធិគយបណ្ដោះអាសន្ន រាប់បញ្ចូលទាំងថ្លៃថែទាំ និងជួសជុលជាបន្ទុករបស់ម្ចាស់កម្មសិទ្ធិ ឬ ប្រតិបត្តិករ ។

ម្ចាស់កម្មសិទ្ធិ ឬប្រតិបត្តិករទីកន្លែងសន្និធិគយបណ្ដោះអាសន្ន ត្រូវធានាដោះស្រាយជូនទីកន្លែងសមរម្យ គ្រប់គ្រាន់ ដោយមិនយកកម្រៃជូនមន្ត្រីគយ ដើម្បីបំពេញការងារដូចមានចែងក្នុងច្បាប់នេះ ។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចចេញប្រកាសកំណត់បានគ្រប់ករណីទាំងឡាយពាក់ព័ន្ធនឹងសន្និធិគយបណ្ដោះអាសន្នរាប់បញ្ចូលទាំងនីតិវិធី និមុត្តិធានា តម្រូវការព័ត៌មាន រយៈពេលសន្និធិ និងប្រភេទទំនិញ ដែលអាចអនុញ្ញាតឱ្យធ្វើសន្និធិ និង ពិន័យលើការធ្វើសន្និធិហួសរយៈពេលកំណត់ ។

## មាត្រា ៤៤.–

ភណ្ឌាគារគយមានដែនកំណត់គឺជាទីកន្លែងដែលទំនិញត្រូវបានដាក់ សម្រាប់រយៈពេលជាក់លាក់មួយ ស្ថិតនៅក្រោមការត្រួតពិនិត្យគយ ដោយមានបញ្ជាក់ពីពេលវេលាច្បាស់លាស់ ។

ការដាក់ទំនិញក្នុងភណ្ឌាគារគយមានដែនកំណត់ ត្រូវបានព្យួរការបង់ពន្ធ អាករ និងការដាក់កម្រិតកំណត់ដែលទំនិញទាំងនោះត្រូវជាប់ ។

ភណ្ឌាគារគយមានដែនកំណត់មានបីប្រភេទ :

ក-ភណ្ឌាគារសាធារណៈ ដែលទទួលបានការអនុញ្ញាតពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចធ្វើប្រតិបត្តិការដោយភ្នាក់ងាររបស់រាជរដ្ឋាភិបាល ឬ ដោយបុគ្គលណាមួយបាន ។ ភណ្ឌាគារនេះត្រូវបានប្រើប្រាស់សម្រាប់ផ្ដល់សេវាដល់បុគ្គលទាំងឡាយដែលមានសិទ្ធិធ្វើសន្និធិទំនិញ ។

ខ-ភណ្ឌាគារឯកជន ដែលត្រូវបានផ្ដល់ការអនុញ្ញាតដោយនាយកទីចាត់ការគយ និងរដ្ឋាករ ត្រូវបានប្រើប្រាស់ដោយឡែក ដោយបុគ្គលណាម្នាក់សម្រាប់ធ្វើសន្និធិទំនិញ ដើម្បីការប្រើប្រាស់ដោយឡែក រាប់បញ្ចូលទាំងប្រតិបត្តិករអគារលក់ទំនិញរួចពន្ធ ។



28/45

គ- ភណ្ឌាគារពិសេស គឺជាប្រភេទភណ្ឌាគារដែលទទួលបានសិទ្ធិពីនាយកទីចាត់ការគយ និងរដ្ឋាករ សម្រាប់រក្សាប្រភេទទំនិញគ្រោះថ្នាក់ប៉ះពាល់ដល់គុណភាពទំនិញដទៃទៀត ឬ អាចត្រូវការទីកន្លែងពិសេសសម្រាប់រក្សាទំនិញទាំងនោះ ។

អាជ្ញាប័ណ្ណសម្រាប់ភណ្ឌាគារគយមានដែនកំណត់ ត្រូវកំណត់នូវល័ក្ខខ័ណ្ឌសម្រាប់ម្ចាស់កម្មសិទ្ធិ និងប្រតិបត្តិករ រាប់បញ្ចូលទាំងទីតាំង សំណង់ គម្រោងអគារ នីតិវិធីសម្រាប់ចាត់ចែង និងគ្រប់គ្រង ។

ចំណាយពាក់ព័ន្ធនឹងភណ្ឌាគារគយមានដែនកំណត់ រាប់បញ្ចូលទាំងថ្លៃថែទាំ និងជួសជុលជាបន្ទុករបស់ម្ចាស់កម្មសិទ្ធិ ឬ ប្រតិបត្តិករ ។

ម្ចាស់កម្មសិទ្ធិ ឬ ប្រតិបត្តិករភណ្ឌាគារគយមានដែនកំណត់ ត្រូវធានាដោះស្រាយជូនទីកន្លែងសមរម្យ គ្រប់គ្រាន់ ដោយមិនយកកម្រៃជូនមន្ត្រីគយ ដើម្បីបំពេញការងារដូចមានចែងក្នុងច្បាប់នេះ ។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចចេញប្រកាសកំណត់គ្រប់ករណីទាំងឡាយពាក់ព័ន្ធនឹងភណ្ឌាគារគយមានដែនកំណត់ រាប់បញ្ចូលទាំងនីតិវិធី និមុត្តិធានា តម្រូវការព័ត៌មាន រយៈពេលសន្និធិ និងប្រភេទទំនិញដែលអាចអនុញ្ញាតឱ្យធ្វើសន្និធិបាន ។

**មាត្រា ៤៥.-**

ប្រតិបត្តិករភណ្ឌាគារគយមានដែនកំណត់ ត្រូវបង់ពន្ធ និងអាករនានា លើទំនិញដែលបានដាក់នៅក្នុងភណ្ឌាគារ ក្នុងករណីដែលបរិមាណ និងគុណភាពខុសពីមានចែងក្នុងប្រតិវេទន៍ភណ្ឌាគារគយ ដោយមិនទាន់គិតដល់ទោសទណ្ឌដែលអាចកើតមាន ។ ប្រសិនបើជាទំនិញជាប់អាយ័តសម្រាប់ការនាំចូលប្រតិបត្តិករភណ្ឌាគារត្រូវតែបង់ផងដែរនូវចំនួនទឹកប្រាក់ស្មើនឹងតម្លៃទំនិញដោយមិនទាន់គិតដល់ទោសទណ្ឌដែលអាចកើតមានបាន ។

នាយកទីចាត់ការគយ និងរដ្ឋាករ អាចអនុញ្ញាតបាន ក្រៅពីការនាំចេញទៅវិញឱ្យបំផ្លាញចោលនូវទំនិញដែលខូចខាតនៅក្នុងភណ្ឌាគារគយក្នុងល័ក្ខខ័ណ្ឌ ដែលសំណល់ពីការបំផ្លាញនេះត្រូវបានបង់ពន្ធ និងអាករ ឬ ឱ្យធ្វើការបង់ពន្ធ និងអាករតាមសភាពទំនិញដែលបានបង្ហាញកន្លងមកចំពោះរដ្ឋបាលគយ ។

ប្រសិនបើមានការអះអាងថា ការបាត់បង់ទំនិញដែលដាក់នៅក្នុងភណ្ឌាគារគយ

មានដែនកំណត់បណ្ដាលមកពីករណីប្រធានស័ក្តិ ឬមូលហេតុពាក់ព័ន្ធនឹងទំនិញប្រតិបត្តិករភណ្ឌាគារត្រូវបានលើកលែងពីការបង់ពន្ធ និង អាករ ឬ ប្រសិនបើជាទំនិញជាប់អាយ័តត្រូវបានរួចពីការបង់ប្រាក់ស្មើនឹងតម្លៃនៃទំនិញនេះ ។

## មាត្រា ៤៦.–

ទំនិញអាចរក្សាទុកក្នុងភណ្ឌាគារគយមានដែនកំណត់ រហូតដល់រយៈពេលពីរ ( ២) ឆ្នាំ គិតពីថ្ងៃចុះបញ្ជិកា ។

ផុតរយៈពេលកំណត់ដូចមានចែងក្នុងកថាខណ្ឌទី ១ នៃមាត្រានេះ ទំនិញត្រូវយកចេញពីភណ្ឌាគារដោយមានការអនុញ្ញាតពីគយ ។ បើមិនដូច្នោះទេ រដ្ឋបាលគយនឹងចេញប្រវេសន៍ដល់ប្រតិបត្តិករភណ្ឌាគារ ដោយតម្រូវឱ្យរើទំនិញចេញ ។ ប្រសិនបើការតម្រូវនេះនៅតែគ្មានប្រសិទ្ធភាពក្នុងរយៈពេលមួយ (១ ) ខែ ចាប់ពីថ្ងៃចេញប្រវេសន៍ ទំនិញត្រូវបានចាត់ទុកជាទំនិញគ្មានការទាមទារ ដូចមានចែងក្នុងមាត្រា ៥៤ នៃច្បាប់នេះ ។ រដ្ឋបាលគយអាចប្រមូលពន្ធ និងអាករ ដែលជំពាក់ពីនិមុត្តិធានាដែលបានតម្កល់ដោយប្រតិបត្តិករភណ្ឌា-គារ ឬ ទំនិញទាំងនោះអាចត្រូវដាក់លក់ ដោយដេញថ្លៃជាសាធារណៈ ដូចមានចែងក្នុងបញ្ញត្តិមាត្រា ៥៥ នៃច្បាប់នេះ ។

ជាការលើកលែង និងលុះត្រាតែទំនិញស្ថិតក្នុងសភាពល្អ រយៈពេលកំណត់ដែលមានចែងក្នុងកថាខណ្ឌទី ១ នៃមាត្រានេះ អាចត្រូវបានពន្យាររហូតដល់ដប់ពីរ ( ១២ )ខែ ដោយរដ្ឋបាលគយតាមការស្នើសុំរបស់ប្រតិបត្តិករភណ្ឌាគារ ។

## មាត្រា ៤៧.–

មន្ត្រីគយអាចធ្វើការឆែកឆេរដែលចាំបាច់នានា និងធ្វើបញ្ជីសារពើភណ្ឌទំនិញក្នុងភណ្ឌាគារ ។ ប្រតិបត្តិករត្រូវបង្ហាញទំនិញសម្រាប់ការធ្វើអធិការកិច្ចនេះ ។

## មាត្រា ៤៨.–

ពន្ធ និងអាករនាំចូលដែលត្រូវប្រមូល គឺជាពន្ធ និងអាករ ដែលមានជាធរមានក្នុងថ្ងៃចុះបញ្ជិកាប្រតិវេទន៍គយដើម្បីយកទំនិញចេញពីភណ្ឌាគារគយមានដែនកំណត់ ។



30/45

**មាត្រា ៤៩.-**

ស្ថិតក្នុងកាលៈទេសៈជាក់ស្តែងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចអនុញ្ញាតឱ្យបង្កើតភណ្ឌាគារផលិតកម្មមានដែនកំណត់ ស្ថិតក្រោមការគ្រប់គ្រងរបស់គយក្នុងគោលបំណងកែច្នៃ និងផលិតទំនិញ ។

លើកលែងតែមានបទប្បញ្ញត្តិផ្ទុយពីនេះ ផលិតផលដែលដាក់ចូល ក្នុងភណ្ឌាគារផលិតកម្មមានដែនកំណត់ត្រូវបានល្យូរពន្ធ និងអាករនាំចូល ។

នៅពេលណាទំនិញត្រូវបានបញ្ចេញពីភណ្ឌាគារផលិតកម្មមានដែនកំណត់សម្រាប់ការប្រើប្រាស់ក្នុងប្រទេស ពន្ធ និងអាករដែលបានលើកលែង ដូចមានចែងក្នុងកថាខណ្ឌទី ២ នៃមាត្រានេះ ត្រូវប្រមូលផ្អែកតាមតារាងពន្ធគយ ហើយអត្រាពន្ធ និងអាករ ដែលត្រូវប្រមូល គឺជាអត្រានៅក្នុងថ្ងៃចុះបញ្ជិកាប្រតិវេទន៍គយនៅពេលដែលទំនិញទទួលបានការអនុញ្ញាតឱ្យយកចូលភណ្ឌាគារនោះ ។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចចេញប្រកាសកំណត់គ្រប់ករណីនានាពាក់ព័ន្ធនឹងភណ្ឌាគារផលិតកម្មមានដែនកំណត់បាន ។

**មាត្រា ៥០.-**

ប្រតិបត្តិការកែច្នៃ ឬ ចំរាញ់តេលសិលាឆៅ ឬ ប៊ីទីមខនិជ ដើម្បីទទួលបានផលិតផលតេលសិលា ត្រូវដាក់ឱ្យស្ថិតក្រោមរបបភណ្ឌាគារផលិតកម្មមានដែនកំណត់ក្រោមការគ្រប់គ្រងរបស់គយ ។

ការល្យូរពន្ធ និងអាករ ដូចមានចែងក្នុងកថាខណ្ឌទី ២ មាត្រា ៤៩ នៃច្បាប់នេះអាចត្រូវបានផ្តល់ឱ្យសម្រាប់ការនាំចូលតេលសិលាឆៅ ឬ ប៊ីទីមខនិជ សម្រាប់កែច្នៃដើម្បីនាំចេញ ។

ល័ក្ខខ័ណ្ឌសម្រាប់ការអនុវត្តបញ្ញត្តិនៃមាត្រានេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ROYAUME DU CAMBODGE * LE MINISTÈRE DU PALAIS ROYAL
ព្រះបរមរាជវាំង



31/45

# ជំពូកទី ៨

# ឯកសារ បញ្ជីគណនេយ្យ កំណត់ត្រា និង ព័ត៌មានផ្សេងទៀត ស្តីពីការនាំចេញនិងនាំចូល

## មាត្រា ៥១.-

បុគ្គលដែលចូលរួម ឬ ពាក់ព័ន្ធនឹងការនាំចេញ និងនាំចូល ត្រូវតែរក្សាឯកសារ បញ្ជីគណនេយ្យ កំណត់ត្រា និងព័ត៌មានផ្សេងទៀត រាប់បញ្ចូលទាំងព័ត៌មានជាសណ្ឋានអេឡិចត្រូនិកដែលត្រឹមត្រូវ និងគ្រប់គ្រាន់ ដែលពាក់ព័ន្ធនឹងការនាំចេញ ឬ នាំចូលនោះ ។

ត្រូវរាប់បញ្ចូលក្នុងកថាខណ្ឌទី ១ នៃមាត្រានេះ នូវអ្នកនាំចូល អ្នកនាំចេញ ជើងសាគយ ប្រតិបត្តិករកន្លែងសន្និធិគយបណ្តោះអាសន្ន និង ភណ្ឌាគារគយមានដែនកំណត់ ប្រតិបត្តិករដឹកជញ្ជូន និងបណ្តាភាគីពាក់ព័ន្ធផ្សេងទៀត ។

ឯកសារ បញ្ជីគណនេយ្យ កំណត់ត្រា និងបណ្តាព័ត៌មានផ្សេងទៀត ដូចមានចែងក្នុងកថាខណ្ឌទី ១ នៃមាត្រានេះ ត្រូវរក្សាទុករយៈពេលដប់ (១០) ឆ្នាំ នៅទីកន្លែងធុរកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា ។

## មាត្រា ៥២.-

តាមសំណើរបស់រដ្ឋបាលគយ បុគ្គលដូចមានចែងក្នុងកថាខណ្ឌទី ១ នៃមាត្រា ៥១ នៃច្បាប់នេះ មានកាតព្វកិច្ចផ្តល់បង្ហាញនូវឯកសារ បញ្ជី គណនេយ្យ កំណត់ត្រា និងបណ្តាព័ត៌មានផ្សេងទៀតពាក់ព័ន្ធនឹងការនាំចេញ និងនាំចូល សម្រាប់ការពិនិត្យផ្ទៀងផ្ទាត់របស់គយ ។

ប្រសិនបើបុគ្គលដែលមានចែងក្នុងកថាខណ្ឌទី ១ នៃមាត្រានេះអវត្តមាន អ្នកតំណាងរបស់បុគ្គលនោះ មានកាតព្វកិច្ចក្នុងការផ្តល់ឯកសារ បញ្ជីគណនេយ្យ កំណត់ត្រា និងបណ្តាព័ត៌មានផ្សេងទៀត ។

ក្នុងករណីដែលមន្ត្រីគយតម្រូវ បុគ្គលដូចមានចែងក្នុងកថាខណ្ឌខាងលើនៃមាត្រានេះត្រូវ ៖

ក-ផ្តល់ឯកសារតាមតម្រូវការរបស់មន្ត្រីគយ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL



32/45

ខ- ឆ្លើយរាល់សំណួរដែលត្រូវបានសួរដោយមន្ត្រីគយ ពាក់ព័ន្ធនឹងកិច្ចការទាំងឡាយដែលកើតឡើងក្រោមបញ្ញត្តិនៃច្បាប់នេះ ។

គ- បើកឱ្យដំណើរការនូវរាល់ឧបករណ៍ដើម្បីផ្តល់បង្ហាញនូវព័ត៌មានចាំបាច់នានាដល់មន្ត្រីគយតាមសំណើ ប្រសិនបើព័ត៌មានដូចមានចែងក្នុងកថាខណ្ឌខាងលើនៃមាត្រានេះត្រូវបានរក្សាទុកដោយមធ្យោបាយអេឡិចត្រូនិក ឬ ឧបករណ៍ផ្សេងទៀត ។

**មាត្រា ៥៣.-**

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចចេញប្រកាសកំណត់តម្រូវការដោយឡែកនានាពាក់ព័ន្ធនឹងឯកសារ បញ្ជីគណនេយ្យ កំណត់ត្រា និងបណ្តាព័ត៌មានផ្សេងទៀតក្រោមបញ្ញត្តិមាត្រា ៥១ នៃច្បាប់នេះ ។

## ជំពូកទី ៩

## ទំនិញគ្មានការទាមទារ

**មាត្រា ៥៤.-**

ទំនិញគ្មានការទាមទារគឺជា :

ក- ទំនិញរក្សាទុកក្នុងទីកន្លែងសន្និធិគយបណ្តោះអាសន្ន ឬ នៅក្នុងភណ្ឌាគារគយមានដែនកំណត់ ដែលហួសរយៈពេលកំណត់ក្រោមបញ្ញត្តិនៃច្បាប់នេះ ។

ខ-ទំនិញផ្ញើតាមប្រៃសណីយ៍ដែលគម្យជនបដិសេធមិនទទួលយក ឬ គម្យជនពុំត្រូវបានរកឃើញនិងមិនអាចបញ្ជូនទំនិញត្រឡប់ទៅអ្នកផ្ញើវិញបាន ។

គ- ទំនិញ និងមធ្យោបាយដឹកជញ្ជូនពុំជាប់អាយ័ត ដែលស្ថិតនៅក្នុងកន្លែងបញ្ចេញទំនិញពីគយ ហើយម្ចាស់បានបោះបង់ចោលជាលាយល័ក្ខណ៍អក្សរ ។

ប្រសិនបើម្ចាស់ទំនិញត្រូវបានស្គាល់ រដ្ឋបាលគយត្រូវជូនដំណឹងជាបន្ទាន់ដល់ម្ចាស់ទំនិញគ្មានការទាមទារថា ទំនិញទាំងនោះនឹងត្រូវដាក់លក់ដោយដេញថ្លៃជាសាធារណៈស្របតាមបញ្ញត្តិមាត្រា ៥៥ នៃច្បាប់នេះ កាលណាពុំមានការទាមទារក្នុងរយៈពេលហុកសិប (៦០) ថ្ងៃ គិតពីថ្ងៃចេញសេចក្តីជូនដំណឹងនេះ ។

ក្នុងករណីពុំអាចរកម្ចាស់ឃើញ ប្រវេសន៍សាធារណៈត្រូវធ្វើតាមពេល និងរបៀប



33/45

ដែលនឹងកំណត់ដោយនាយកទីចាត់ការគយ និងរដ្ឋាករ ដើម្បីជាការជូនដំណឹងដល់ម្ចាស់ទំនិញ ។ ក្នុងរយៈពេលហុកសិប (៦០) ថ្ងៃ គិតចាប់ពីថ្ងៃចេញប្រវេសន៍នេះ ម្ចាស់ទំនិញត្រូវធ្វើការទាមទារទំនិញរបស់ខ្លួន ។ ប្រសិនបើហួសរយៈពេលនេះ ទំនិញនឹងត្រូវដាក់លក់ដោយដេញថ្លៃជាសាធារណៈស្របតាមបញ្ញត្តិនៃមាត្រា ៥៥ នៃច្បាប់នេះ ។

ក្នុងរយៈពេលដូចមានចែងក្នុងកថាខណ្ឌទី ២ និងកថាខណ្ឌទី ៣ នៃមាត្រានេះ ទំនិញគ្មានការទាមទារអាចអនុញ្ញាតឱ្យយកចេញពីគយបាន ក្រោយពីបានបង់ពន្ធ អាករ និងកម្រៃផ្សេងៗ និងទោសទណ្ឌនានា រួមទាំងល័ក្ខខ័ណ្ឌកម្រិតកំណត់ទាំងឡាយត្រូវបានបំពេញរួច ។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចចេញប្រកាសកំណត់ករណីដែលទំនិញគ្មានការទាមទារអាចត្រូវបំផ្លាញចោល លក់ដោយដេញថ្លៃជាបន្ទាន់ ត្រូវបោះបង់ចោល ឬត្រូវប្រើប្រាស់សម្រាប់ប្រយោជន៍សាធារណៈផ្អែកតាមលក្ខណៈ ឬ តម្លៃទាបនៃទំនិញដោយធ្វើសេចក្តីជូនដំណឹងជាលាយល័ក្ខណ៍អក្សរជូនម្ចាស់ទំនិញ ឬ ចេញប្រវេសន៍សាធារណៈ ប្រសិនបើរកម្ចាស់ពុំឃើញ ។

**មាត្រា ៥៥.-**

ការលក់ទំនិញគ្មានការទាមទារ ត្រូវដាក់លក់ដោយដេញថ្លៃជាសាធារណៈ ។

នាយកទីចាត់ការគយ និងរដ្ឋាករ អាចកំណត់ថ្លៃអប្បបរមាបានសម្រាប់ទំនិញដែលត្រូវដាក់លក់ដោយដេញថ្លៃ ។ ប្រសិនបើទំនិញមិនអាចត្រូវលក់ដាច់តាមថ្លៃនេះទេ នាយកទីចាត់ការគយ និងរដ្ឋាករ អាចកំណត់ថ្លៃអប្បបរមាថ្មីមួយ ឬ សុំការសម្រេចពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីបោះបង់ចោល ឬ ទុកប្រើប្រាស់សម្រាប់ផលប្រយោជន៍សាធារណៈ ។

ផលបានមកពីការលក់ត្រូវទូទាត់សងប្រាក់ពន្ធ និងអាករ ដែលមិនទាន់បានបង់កម្រៃ និងបន្ទុកផ្សេងៗ និងចំណាយរៀបចំការដាក់លក់ ដោយដេញថ្លៃ ។ ម្ចាស់ទំនិញអាចទាមទារយកនូវទឹកប្រាក់នៅសល់ក្រោយពីការទូទាត់នេះបាន ក្នុងរយៈពេលប្រាំមួយ (៦) ខែ តាមសេចក្តីជូនដំណឹងរបស់រដ្ឋបាលគយ ដែលត្រូវធ្វើឡើងក្នុងរង្វង់រយៈពេលប្រាំពីរ (៧) ថ្ងៃ បន្ទាប់ពីការលក់ដោយដេញថ្លៃ ។ ហួសរយៈពេលកំណត់នេះ ប្រសិនជាមិនមាន

ការទាមទារយកទឹកប្រាក់នេះទេ នឹងក្លាយជាទ្រព្យសម្បត្តិរបស់រដ្ឋ ។

## ជំពូកទី ១០
## សិទ្ធិអំណាច និង ភារកិច្ច

**មាត្រា ៥៦.-**

មន្ត្រីគយមានសិទ្ធិអំណាចដូចមានចែងក្នុងច្បាប់នេះនៅក្នុងវង់អំណាចគយ ។ ក្នុងករណីដែលទំនិញត្រូវបានកំណត់ក្រោមបញ្ញត្តិនៃកថាខណ្ឌទី ២ ក្នុងមាត្រា ៨ នៃច្បាប់នេះ សិទ្ធិអំណាចរបស់មន្ត្រីគយត្រូវគ្របដណ្តប់នៅទូទាំងដែនគយ ។

ចំពោះទំនិញនាំចេញ ឬ នាំចូល មន្ត្រីគយមានសិទ្ធិអំណាចដូចតទៅ :

ក-ពិនិត្យទំនិញ ហើយបើក ឬ បញ្ជាឱ្យបើកកញ្ចប់ណាមួយ ឬ កុងតឺន័រទំនិញនិងអាចដកយកទំនិញបាន តាមចំនួនសមស្របសម្រាប់ការពិនិត្យ ។

ខ- ឃាត់ បញ្ឈប់ ឡើង ចូល និងត្រួតពិនិត្យឆែកឆេរ មធ្យោបាយដឹកជញ្ជូនទំនិញណាមួយ និងបញ្ជាឱ្យនាំមធ្យោបាយដឹកជញ្ជូនទំនិញនោះទៅការិយាល័យគយ ឬ ទីកន្លែងសមរម្យផ្សេងទៀតដើម្បីធ្វើការត្រួតពិនិត្យឆែកឆេរ ។

គ-ឆែកឆេរលំនៅស្ថានឯកជន ឬ ទីកន្លែងធុរកិច្ច ដើម្បីប្រមូលភ័ស្តុតាង ឬឃាត់ទុកទំនិញជាបណ្តោះអាសន្ន តាមបទប្បញ្ញត្តិ និងច្បាប់នានានៃព្រះរាជាណាចក្រកម្ពុជាក្នុងករណីមានការសង្ស័យដែលមានមូលដ្ឋានគួរឱ្យទុកចិត្តបានថាមានការប្រព្រឹត្តបទល្មើស ។

ឃ- ត្រួតពិនិត្យអត្តសញ្ញាណជនណាមួយដែលចូល ចេញដែនគយ ឃាត់ បញ្ឈប់ សួរ និងឆែកឆេរជននោះ ប្រសិនបើមន្ត្រីគយសង្ស័យថា ជននោះមានលាក់ទំនិញ ឬ របស់អ្វីផ្សេងទៀតនៅជុំវិញខ្លួននិងនៅក្នុងខ្លួនរបស់គេ ដែលអាចជាភ័ស្តុតាងនៃការរំលោភច្បាប់នេះ ឬ ច្បាប់ផ្សេងទៀតនៃព្រះរាជាណាចក្រកម្ពុជា ។

ចំណាយលើការត្រួតពិនិត្យដូចមានចែងក្នុងវាក្យខណ្ឌ ក និងវាក្យខណ្ឌ ខ កថាខណ្ឌទី ២ នៃមាត្រានេះ ជាបន្ទុករបស់ម្ចាស់ ឬ អ្នកទទួលកាន់កាប់ទំនិញ ឬ មធ្យោបាយដឹកជញ្ជូននោះ ។

ង



35/45

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចចេញប្រកាសកំណត់នីតិវិធីសម្រាប់ការធ្វើអធិការកិច្ច និងការត្រួតពិនិត្យ ។

**មាត្រា ៥៧.-**

តាមពេលវេលាដែលច្បាប់អនុញ្ញាត មន្ត្រីគយមានសិទ្ធិចូលក្នុងទីតាំង ឬ ទីកន្លែងដែលរក្សាទុកឯកសារដូចមានចែងក្នុងមាត្រា ៥១ នៃច្បាប់នេះ ហើយមានសិទ្ធិធ្វើសវនកម្ម ឬពិនិត្យឆែកឆេរឯកសារទាំងនោះ ដែលពាក់ព័ន្ធនឹងកិច្ចចម្លងការដោយឡែក ឬភាពត្រឹមត្រូវ និងអាចទទួលយកបាននៃប្រព័ន្ធកត់ត្រាដោយដៃ ឬ ប្រព័ន្ធអេឡិចត្រូនិក ដែលនៅក្នុងប្រព័ន្ធនោះ ឯកសារទាំងនេះត្រូវបានបង្កើត និងរក្សាទុក ។

មន្ត្រីគយអាចធ្វើអធិការកិច្ចបានលើឯកសារ កំណត់ត្រា និងព័ត៌មានផ្សេងទៀត ឬ ទ្រព្យសម្បត្តិ កិច្ចដំណើរការ ឬ កិច្ចការផ្សេងទៀត ដែលមន្ត្រីគយយល់ថាចាំបាច់ និងពាក់ព័ន្ធនឹងគោលដៅនៃការប្រមូលពន្ធ និង អាករក្រោមបញ្ញត្តិនៃច្បាប់នេះ សម្រាប់អនុវត្តតាមគោលបំណងបំពេញនូវភារកិច្ចរបស់មន្ត្រីគយ ឬ ក្នុងគោលបំណងនៃការប្រមូលព័ត៌មានដែលតម្រូវដោយច្បាប់នេះ ។

មន្ត្រីគយមានសិទ្ធិចេញ និងចូលទៅគ្រប់ទីតាំង កន្លែង អគារ និង ទីកន្លែងនានាព្រមទាំងមានសិទ្ធិឆែកឆេរ ឯកសារ កំណត់ត្រា និងព័ត៌មានផ្សេងទៀត ទោះបីជាស្ថិតក្រោមការគ្រប់គ្រង ត្រួតពិនិត្យរបស់អ្នកទទួលបានអាជ្ញាប័ណ្ណ អ្នកនាំចេញ ឬ អ្នកនាំចូល ឬ បុគ្គលណាផ្សេងទៀត ។

មន្ត្រីគយអាចដកស្រង់ព័ត៌មាន ឬ ថតចម្លងនូវកំណត់ត្រា ឬ ឯកសារនានាដកហូតយកដោយមានកំណត់ហេតុនិងរក្សាទុកឯកសារដែលបានបង្ហាញពាក់ព័ន្ធនឹងការប្រកាសណាមួយ ឬ តាមតម្រូវការនៃច្បាប់នេះ ដោយគ្មានជាប់បន្ទុកចំណាយអ្វីឡើយ ។

តាមសំណើរបស់ជនដែលកាន់កាប់ឯកសារ មន្ត្រីគយត្រូវផ្តល់ដល់ជននោះនូវឯក-សារថតចម្លងត្រឹមត្រូវដោយមានការបញ្ជាក់ពីរដ្ឋបាលគយ ។

**មាត្រា ៥៨.-**

មន្ត្រីគយដែលបានសច្ចាប្រណិធាន អាចបំពេញមុខងារជាមន្ត្រីនគរបាលយុត្តិធម៌បាន លុះត្រាតែសាមីខ្លួនបានទទួលនីតិសម្បទាពីអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ។



36/45

មន្ត្រីគយដែលបានទទួលនីតិសម្បទាជានគរបាលយុត្តិធម៌ត្រូវធ្វើ និងចុះហត្ថលេខាលើកំណត់ហេតុបទល្មើសគយតាមដែនសមត្ថកិច្ចរបស់ខ្លួន ។

នៅពេលបំពេញបេសកកម្មស្រាវជ្រាវ ទប់ស្កាត់ និងបង្ក្រាបបទល្មើសគយ មន្ត្រីគយត្រូវមានលិខិតបញ្ជាបេសកកម្ម និងត្រូវស្លៀកពាក់ឯកសណ្ឋាន ពាក់សញ្ញាសម្គាល់ ពាក់ឋានន្តរសក្តិ លើកលែងតែមានការណែនាំដោយឡែកពីនាយកទីចាត់ការគយ និងរដ្ឋាករ ។

សំលៀកបំពាក់ឯកសណ្ឋាន សញ្ញាសម្គាល់ និងឋានន្តរសក្តិរបស់មន្ត្រីគយត្រូវកំណត់ដោយអនុក្រឹត្យ ។

## មាត្រា ៥៩.-

មន្ត្រីគយមានសិទ្ធិកាន់ និងប្រើប្រាស់អាវុធក្នុងពេលបំពេញភារកិច្ចតាមកាលៈទេសៈដូចតទៅ :

-សម្រាប់ការពារខ្លួនស្របច្បាប់

-បើពុំអាចឃាត់ បញ្ឈប់ មធ្យោបាយដឹកជញ្ជូន ដែលសង្ស័យថា ពាក់ព័ន្ធនឹងការរត់ពន្ធ ឬសកម្មភាពល្មើសផ្សេងទៀត ដែលអ្នកបើកបរពុំព្រមឈប់តាមការបញ្ជាឱ្យឈប់

- សម្រាប់ហេតុផលផ្សេងទៀត ដូចមានចែងក្នុងបទប្បញ្ញត្តិ និង ច្បាប់នានានៃព្រះរាជាណាចក្រកម្ពុជា ។

អាវុធដែលមន្ត្រីគយ និងរដ្ឋាករ ប្រើប្រាស់ក្នុងកិច្ចប្រតិបត្តិការបំពេញភារកិច្ចត្រូវបានបំពាក់ និងគ្រប់គ្រងដោយក្រសួងមហាផ្ទៃ ។

## មាត្រា ៦០.-

មន្ត្រីគយដែលបានសច្ចាប្រណិធានមានលក្ខណៈសម្បត្តិជានគរបាលយុត្តិធម៌អាចសម្រេចឃាត់ខ្លួនបានក្នុងរយៈពេលសែសិបប្រាំបី (៤៨) ម៉ោងយ៉ាងយូរ ដោយអនុវត្តស្របតាមក្រមនីតិវិធីព្រហ្មទណ្ឌ ។

## មាត្រា ៦១.-

ជនគ្រប់រូបមិនត្រូវបង្កឧបសគ្គ ឬ ធ្វើឱ្យរាំងស្ទះដល់មន្ត្រីគយក្នុងការប្រើអំណាចស្របច្បាប់របស់ខ្លួនដូចមានចែងក្នុងច្បាប់នេះ ឬ ច្បាប់ផ្សេងទៀតនៃព្រះរាជាណាចក្រកម្ពុជា ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

## មាត្រា ៦២.-

អ្នកបើកបរមធ្យោបាយដឹកជញ្ជូន ក្នុងការធ្វើចលនាមធ្យោបាយដឹកជញ្ជូនរបស់ខ្លួន ត្រូវគោរពតាមបញ្ជារបស់មន្ត្រីគយ ។

មន្ត្រីគយអាចប្រើប្រាស់បរិក្ខារសមស្រប ដើម្បីឃាត់បញ្ឈប់មធ្យោបាយដឹកជញ្ជូន កាលបើអ្នកបើកបរមិនឈប់តាមការបញ្ជាឱ្យឈប់ ។

នៅពេលមានការស្នើសុំអាជ្ញាធរមានសមត្ថកិច្ច នគរបាល និង យោធា ត្រូវជួយជាបន្ទាន់ដល់មន្ត្រីគយក្នុងការបំពេញភារកិច្ចរបស់ខ្លួនដូចមានចែងក្នុងច្បាប់នេះ ។

## មាត្រា ៦៣.-

មន្ត្រីគយមិនត្រូវចូលរួមក្នុងសកម្មភាពពាណិជ្ជកម្ម តាមរបៀបពាក់ព័ន្ធ ឬ ទំនាស់ជាមួយនឹងភារកិច្ចផ្លូវការរបស់ខ្លួន ។

ព័ត៌មានដែលទទួលបានដោយមន្ត្រីគយនៅក្នុងការគ្រប់គ្រង ឬ ការអនុវត្តច្បាប់នេះអាចប្រើប្រាស់បានសម្រាប់តែគោលបំណងដែលមានចែងក្នុងច្បាប់នេះ លើកលែងតែមានការអនុញ្ញាតដោយឡែក ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## មាត្រា ៦៤.-

មន្ត្រីគយដែលប្រព្រឹត្តបទល្មើសលើច្បាប់នេះនិងបញ្ញត្តិផ្សេងទៀត នឹងត្រូវទទួលការផ្តន្ទាទោសតាមច្បាប់ជាធរមាន ។

## មាត្រា ៦៥.-

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចចេញប្រកាសកំណត់ល័ក្ខខ័ណ្ឌនានាពាក់ព័ន្ធនឹងការផ្តល់រង្វាន់លើកទឹកចិត្តដល់មន្ត្រីគយដែលមានស្នាដៃ និងដល់បណ្តាស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ រាប់បញ្ចូលទាំងកងកម្លាំងប្រដាប់អាវុធនៃកងយោធពលខេមរភូមិន្ទ កងនគរបាលជាតិ អាជ្ញាធរដែនដីគ្រប់ជាន់ថ្នាក់ព្រមទាំងជនទាំងឡាយណាដែលបានចូលរួមសហការ និងគាំទ្រដល់រដ្ឋបាលគយក្នុងការអនុវត្តច្បាប់នេះ ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *
38/45

**មាត្រា ៦៦.–**

មន្ត្រីគយមានសិទ្ធិឃាត់ទុកបណ្ដោះអាសន្ននូវទំនិញ និងមធ្យោបាយដឹកជញ្ជូនដែលចូលរួមក្នុងការរំលោភបំពានលើបទប្បញ្ញត្តិនានានៃច្បាប់នេះ ។ ទំនិញ និងមធ្យោបាយដឹកជញ្ជូនទាំងនោះ អាចជាកម្មវត្ថុនៃការរឹបអូសដោយតុលាការមានសមត្ថកិច្ច ។

នៅក្រៅវង់អំណាចគយ ការឃាត់ទុកបណ្ដោះអាសន្ន អាចត្រូវធ្វើឡើងនៅក្នុងការិយាល័យគយ កន្លែងសន្និធិគយបណ្ដោះអាសន្ន ភណ្ឌាគារគយមានដែនកំណត់ និងកន្លែងផ្សេងទៀត ដែលស្ថិតនៅក្រោមអនុរក្សរបស់រដ្ឋបាលគយ ។

ទំនិញដូចមានចែងនៅក្នុងកថាខណ្ឌទី ២ មាត្រា ៨ នៃច្បាប់នេះ អាចត្រូវបានឃាត់ទុកជាបណ្ដោះអាសន្ននៅគ្រប់ទីកន្លែងក្នុងដែនគយ ។

ការឃាត់ទុកបណ្ដោះអាសន្ន អាចត្រូវបានអនុវត្តផងដែរនៅគ្រប់ទីកន្លែងក្នុងដែនគយ ក្នុងករណីមានការដេញប្រផាប់ចាប់ប្រភីង ឬ ការរកឃើញដោយចៃដន្យនូវទំនិញដែលមិនស៊ីគ្នានឹងការប្រកាស ឬ ឯកសារដែលមានជាប់នឹងអ្នកកាន់កាប់ ។

មន្ត្រីគយមានសិទ្ធិថតចម្លង ឬ ដកហូតឯកសារ ឬ វត្ថុផ្សេងៗទៀត ដែលជាភស្តុតាងនៃការរំលោភបំពានច្បាប់នេះ ។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចចេញប្រកាសកំណត់នីតិវិធីពាក់ព័ន្ធនឹងការឃាត់ទុកបណ្ដោះអាសន្ននូវទំនិញ មធ្យោបាយដឹកជញ្ជូន ឯកសារ និងវត្ថុផ្សេងៗទៀត ព្រមទាំងការថតចម្លងឯកសារទាំងនោះ ។

**មាត្រា ៦៧.–**

ឱ្យតែកាលៈទេសៈបើកឱ្យធ្វើបាន ទំនិញ មធ្យោបាយដឹកជញ្ជូន ឬ វត្ថុដែលបានឃាត់ទុកបណ្ដោះអាសន្នផ្សេងៗត្រូវបញ្ជូនមកការិយាល័យគយដែលនៅជិតបំផុតនឹងកន្លែងដែលបានឃាត់ទុកនោះ ។ ប្រសិនបើមានការិយាល័យគយច្រើនស្ថិតក្នុងតំបន់តែមួយ វត្ថុឃាត់ទុកបណ្ដោះអាសន្នអាចត្រូវបានដឹកជញ្ជូនទៅការិយាល័យណាមួយក៏បាន ។ កាលបើមិនអាចនាំយកភ្លាមទៅកាន់ការិយាល័យគយ ឬ បើពុំមានការិយាល័យគយនៅក្នុងតំបន់នោះទេ វត្ថុឃាត់ទុកបណ្ដោះអាសន្នអាចត្រូវបានប្រគល់ឱ្យជនជាប់ចោទ ឬ តតិយជននៅកន្លែងឃាត់ទុក ឬ កន្លែងផ្សេងទៀតជាអ្នកថែរក្សាទុក ។

ប្រសិនទំនិញឃាត់ទុកបណ្តោះអាសន្ន មិនជាប់អាយ័ត ទំនិញ មធ្យោបាយដឹកជញ្ជូន ឯកសារ និងវត្ថុចាប់ឃាត់ផ្សេងទៀតមិនតម្រូវសម្រាប់ជាភ័ស្តុតាង វត្ថុឃាត់ទុកទាំងនេះអាចត្រូវបានប្រគល់ទៅម្ចាស់ក្រោយ ពេលបានតម្កល់នូវនិមុត្តិធានាដូចមានចែងក្រោមបញ្ញត្តិមាត្រា ៤១ នៃច្បាប់នេះ ។

ទំនិញឃាត់ទុកបណ្តោះអាសន្នដែលមិនជាប់អាយ័ត ឬ កម្រិតកំណត់មធ្យោបាយដឹកជញ្ជូន ឬ វត្ថុផ្សេងទៀតដែលប្រើប្រាស់សម្រាប់លាក់បំបាំង ឬ ដឹកជញ្ជូនទំនិញទាំងនោះ ត្រូវប្រគល់ជូនម្ចាស់វិញ បន្ទាប់ពីបានបង់ពន្ធ អាករ បន្ទុកផ្សេងៗ និងប្រាក់ពិន័យគ្រប់ចំនួន ។

## មាត្រា ៦៨.-

មន្ត្រីគយដែលធ្វើការឃាត់ទំនិញ ត្រូវធ្វើកំណត់ហេតុឃាត់ទុកដោយមិនបង្អែបង្អង់ ។

បើជនល្មើសវត្តមាន ត្រូវចុះក្នុងកំណត់ហេតុថា បានអានសេចក្តីឱ្យសាមីខ្លួនស្តាប់ បានហៅសាមីខ្លួនឱ្យអាន និងចុះហត្ថលេខា ព្រមទាំងបានផ្តល់ជាបន្ទាន់នូវកំណត់ហេតុមួយច្បាប់ដល់ជននោះ ។

បើជនល្មើសអវត្តមាន សេចក្តីចម្លងកំណត់ហេតុត្រូវបិទផ្សាយក្នុងរង្វង់ម្ភៃបួន (២៤) ម៉ោង បន្ទាប់ពីកំណត់ហេតុត្រូវបានធ្វើរួចនៅការិយាល័យគយជិតបំផុត ឬ នៅការិយាល័យអាជ្ញាធរមូលដ្ឋានជិតបំផុត ប្រសិនបើទីនោះ គ្មានការិយាល័យគយ ។

សេចក្តីលម្អិតនានាពាក់ព័ន្ធនឹងទម្រង់ខ្លឹមសារ នីតិវិធី សម្រាប់ការរៀបចំ និងការដាក់ជូនទៅតុលាការនៃកំណត់ហេតុដូចមានចែងក្នុងកថាខណ្ឌទី ១ នៃមាត្រានេះ ត្រូវកំណត់ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

## មាត្រា ៦៩.-

ក្នុងករណីការឃាត់ទុកត្រូវបានធ្វើឡើងលើនាវា និងកប៉ាល់មានជាន់ថ្នាក់ កាលបើការរើទំនិញចេញពុំអាចធ្វើបានភ្លាម អ្នកឃាត់ទុកត្រូវបិទត្រាគយលើសន្ទះ ឃ្លប់ និងគម្របនៃនាវានោះ ។

## មាត្រា ៧០.-

ក្នុងករណីដែលការឃាត់ទុកត្រូវបានធ្វើនៅក្នុងលំនៅស្ថាន ទំនិញមិនជាប់អាយ័ត



40/45

មិនត្រូវនាំយកទៅទីណាឡើយ បើជនជាប់ចោទបានតម្កល់និមុត្តិធានា ស្របតាមបញ្ញត្តិមាត្រា ៤១ នៃច្បាប់នេះ ។ ប្រសិនបើជនជាប់ចោទមិនបានតម្កល់និមុត្តិធានា ឬ បើជាទំនិញជាប់អាយ័ត ទំនិញនោះត្រូវដឹកជញ្ជូនទៅកាន់ការិយាល័យគយជិតបំផុត ឬ ប្រគល់ឱ្យតតិយជនថែរក្សានៅកន្លែងឃាត់ទុក ឬ នៅកន្លែងផ្សេងទៀត ។

**មាត្រា ៧១.-**

បុគ្គលដែលត្រូវរងនូវទោសទណ្ឌ ឬ ការឃាត់ទុកនូវទំនិញ មធ្យោបាយដឹកជញ្ជូន ឬវត្ថុផ្សេងទៀត អាចតវ៉ាជាលាយលក្ខណ៍អក្សរទៅនាយកទីចាត់ការគយ និងរដ្ឋាករក្នុងអំឡុងពេលសាមសិប ( ៣០ ) ថ្ងៃ ក្រោយបានទទួលសេចក្ដីជូនដំណឹងពីទោសទណ្ឌ ឬ ការឃាត់ទុក ដោយបញ្ជាក់ពីមូលហេតុនៃការតវ៉ា និងតម្កល់និមុត្តិធានាស្របតាមបញ្ញត្តិមាត្រា ៤១ នៃច្បាប់នេះ ។

នាយកទីចាត់ការគយ និងរដ្ឋាករ ត្រូវចេញសេចក្ដីសម្រេចលើការតវ៉ាក្នុងអំឡុងពេលហុកសិប ( ៦០ ) ថ្ងៃ គិតចាប់ពីថ្ងៃដែលបានទទួលពាក្យតវ៉ា បើមិនដូច្នោះទេ ការតវ៉ានោះត្រូវបានចាត់ទុកថាបានទទួលការយល់ព្រម ។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចចេញប្រកាសកំណត់នីតិវិធីពាក់ព័ន្ធនឹងដំណើរការតវ៉ានេះ ។

## ជំពូកទី ១១

## ទោសប្បញ្ញត្តិ

**មាត្រា ៧២.-**

បុគ្គលណាដែលនាំចេញ ឬ នាំចូល ឬ ប៉ុនប៉ងនាំចេញ ឬ ប៉ុនប៉ងនាំចូលទំនិញដោយរំលោភបំពានលើច្បាប់ ឬ បញ្ញត្តិនានា ត្រូវចាត់ទុកថាបានប្រព្រឹត្តបទល្មើស ។

បុគ្គលណាដែលប្រព្រឹត្តបទល្មើសគយ ត្រូវផ្តន្ទាទោសពិន័យរដ្ឋបាលដែលកំណត់ដោយរដ្ឋបាលគយនិងទោសទណ្ឌតាមផ្លូវតុលាការដែលកំណត់ ដោយតុលាការមានសមត្ថកិច្ច ឬ ទោសណាមួយនៃទោសទាំងពីរ ។



41/45

## មាត្រា ៧៣.-

ជនណាដែលរំលោភបំពានកម្រិតទាបលើបញ្ញត្តិ និងបទប្បញ្ញត្តិនៃច្បាប់នេះដោយរាប់បញ្ចូលទាំងការចុះមិនត្រឹមត្រូវ ការភ្លេច ឬ ការខកខានចុះនូវស្ទួចនាណាមួយ ដែលត្រូវរៀបរាប់ក្នុងប្រតិវេទន៍គយ និងការខកខានបំពេញការតម្រូវ និងកាតព្វកិច្ចនានាដែលមិនប៉ះពាល់ដល់ពន្ធ អាករ អាយ័តភាព ឬការកម្រិតកំណត់ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីមួយរយពាន់(១០០.០០០) រៀល ទៅប្រាំរយពាន់ (៥០០.០០០) រៀល ប្រសិនបើអនិយ័តភាពនេះមិនត្រូវបានរងការពិន័យធ្ងន់ធ្ងរជាងនៅក្នុងច្បាប់នេះ ។

## មាត្រា ៧៤.-

ជនណាដែលរំលោភបំពានលើបញ្ញត្តិ និងបទប្បញ្ញត្តិនៃច្បាប់នេះ ដោយរាប់បញ្ចូលទាំងការរំលោភដូចមានចែងក្នុងមាត្រា ៧៣ នៃច្បាប់នេះ ដែលមានផលប៉ះពាល់ដល់ពន្ធ ឬ អាករ និងក្នុងករណីដែលទំនិញពុំជាប់អាយ័ត ឬ កម្រិតកំណត់ ត្រូវផ្តន្ទាទោសរដ្ឋបាលដោយពិន័យជាប្រាក់ស្មើនឹងមួយ (១) ដង ទៅ បី(៣) ដង នៃប្រាក់ពន្ធ និងអាករដែលបានគេចវេះ និង ត្រូវរងនូវទោសទណ្ឌតាមផ្លូវតុលាការ ដោយត្រូវរឹបអូសទំនិញ មធ្យោបាយដឹកជញ្ជូន និងវត្ថុផ្សេងទៀតដែលប្រើសម្រាប់លាក់បំបាំងទំនិញល្មើស ឬ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពីមួយ (១) ខែ ទៅមួយ (១) ឆ្នាំ ឬ ទោសណាមួយនៃទោសទាំងពីរ ។

ត្រូវបានចាត់ទុកជាប្រភេទបទល្មើស ដូចមានចែងក្នុងកថាខណ្ឌទី ១ នៃមាត្រានេះ :

ក-ការខកខានរាយការណ៍អំពីទំនិញជូនរដ្ឋបាលគយ ស្របតាមបញ្ញត្តិមាត្រា ១០ និងមាត្រា ១៦ នៃច្បាប់នេះ ។

ខ-ការរើទំនិញចេញពីមធ្យោបាយដឹកជញ្ជូន មុនពេលរាយការណ៍ជូនរដ្ឋបាលគយដូចមានចែងក្នុងបញ្ញត្តិមាត្រា ១២ នៃច្បាប់នេះ ។

គ-ការបើក ការហែក គាស់ ការធ្វើឱ្យរបើក ឬ រហែកកញ្ចប់ទំនិញនាំចូល ដែលមិនទាន់ទទួលបានការអនុញ្ញាតពីរដ្ឋបាលគយឱ្យយកចេញ ការធ្វើឱ្យបែកបាក់ ខូចខាត ត្រា សោ ដែលបានចាក់ ឬ បិទភ្ជាប់លើទំនិញ មធ្យោបាយដឹកជញ្ជូន កន្លែងសន្និធិគយបណ្តោះអាសន្ន ភណ្ឌាគារគយមានដែនកំណត់ ឬ កន្លែងផ្សេងទៀតដែលតម្រូវដោយច្បាប់នេះ ។

ឃ-ការយកទំនិញចេញពីកន្លែងបំពេញបែបបទបញ្ចេញទំនិញពីគយ កន្លែងសន្និធិគយបណ្តោះអាសន្ន ឬ ភណ្ឌាគារគយមានដែនកំណត់ ដោយគ្មានការអនុញ្ញាតពីរដ្ឋបាលគយ ។

ង-ការខកខានដាក់ប្រតិវេទនីគយស្របតាមបញ្ញត្តិមាត្រា ២៩ នៃច្បាប់នេះ ។

ច-ការខកខានបំពេញតាមបញ្ញត្តិមាត្រា ៣០ នៃច្បាប់នេះ ។

ឆ- ការលក់ ការផ្ទេរ ការបង្វែរ ឬ ការបោះបង់ចោលទំនិញនាំចូល ដែលបានទទួលការលើកលែងពន្ធ និងអាករផ្សេងៗ ដូចចែងក្នុងមាត្រា ២៦ និងមាត្រា ២៧ នៃច្បាប់នេះដោយគ្មានការអនុញ្ញាតពីរដ្ឋបាលគយ ។

ជ-ការខកខានអនុវត្តតាមល័ក្ខខ័ណ្ឌដែលកំណត់ដោយរដ្ឋបាលគយ ពាក់ព័ន្ធនឹងទំនិញដែលស្ថិតក្រោមរបបព្យួរពន្ធ និងអាករ ស្របតាមបញ្ញត្តិនៃច្បាប់នេះ ។

ឈ-ការប្រព្រឹត្ត ការយល់ព្រម ឬ ចូលរួមក្នុងការប្រកាសដោយផ្ទាល់មាត់ ឬជាលាយលក្ខ័ណអក្សរដែលនាំឱ្យមានភាពមិនត្រឹមត្រូវ ក្លែងបន្លំ ឬ បោកបញ្ឆោតដែលផ្ទុយនឹងច្បាប់នេះ ។

ញ-ការរត់ពន្ធ ឬ ការប៉ុនប៉ងរត់ពន្ធទំនិញ ។

ដ- ការកាន់កាប់ លក់ ទិញ ផ្ទេរ ឬ ទទួលដោយគ្មានការអនុញ្ញាតពីរដ្ឋបាលគយនូវទំនិញដែលបាននាំចូលដោយរំលោភនឹងបញ្ញត្តិនៃច្បាប់នេះ ។

ជនណាប្រព្រឹត្តបទល្មើសដូចខាងក្រោម ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីមួយលាន (១.០០០.០០០)រៀល ដល់ប្រាំលាន(៥.០០០.០០០)រៀល និងផ្តន្ទាទោសដាក់ពន្ធនាគារពីមួយ (១) ខែ ដល់ប្រាំមួយ (៦) ខែ ឬ ទោសណាមួយនៃទោសទាំងពីរនេះ :

ក-ការខកខានបំពេញតាមបញ្ញត្តិ ដូចមានចែងក្នុងមាត្រា ៥១ មាត្រា ៥២ និងមាត្រា ៥៣ នៃច្បាប់នេះ ។

ខ-ជនណាដែលបង្កឧបសគ្គ ឬ ធ្វើឱ្យរាំងស្ទះដល់មន្ត្រីគយ តាមបញ្ញត្តិដូចមានចែងក្នុងមាត្រា ៦១ នៃច្បាប់នេះ ។

គ- អ្នកបើកបរមធ្យោបាយដឹកជញ្ជូនដែលមិនគោរពតាមបញ្ជារបស់មន្ត្រីគយស្របតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ក្នុងមាត្រា ៦២ នៃច្បាប់នេះ ។



ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *
ក្រសួងព្រះបរមរាជវាំង
43/45

**មាត្រា ៧៥.-**

ជនណាដែលរំលោភបំពានលើបញ្ញត្តិ និងបទប្បញ្ញត្តិនៃមាត្រា ៧៤ នៃច្បាប់នេះ ដែលពាក់ព័ន្ធនឹងទំនិញជាប់កម្រិតកំណត់ ឬ ជាប់អាយ័តដូចមានចែងក្នុងកថាខណ្ឌទី ១ នៃមាត្រា ៨ នៃច្បាប់នេះ លើកលែងតែវាក្យខណ្ឌ ជ នៃកថាខណ្ឌទី ១ ក្នុងមាត្រា ៧៤ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសរដ្ឋបាល ដោយពិន័យជាប្រាក់រហូតដល់ បី (៣) ដង នៃតម្លៃទំនិញនិងមធ្យោបាយដឹកជញ្ជូន និងត្រូវរងទោសទណ្ឌតាមផ្លូវតុលាការ ដោយរឹបអូសទំនិញ មធ្យោ-បាយដឹកជញ្ជូន និងវត្ថុផ្សេងទៀត ដែលប្រើប្រាស់សម្រាប់លាក់បំបាំងទំនិញល្មើស ឬ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពីមួយ (១) ឆ្នាំ ដល់ ប្រាំ (៥) ឆ្នាំ ឬ ទោសណាមួយនៃទោសទាំងពីរ ។

**មាត្រា ៧៦.-**

ក្នុងករណីមិនរាងចាល បទល្មើសដូចមានចែងក្នុងច្បាប់នេះត្រូវផ្តន្ទាទោសទ្វេឡើងទាំងទោសពិន័យរដ្ឋបាល ទាំងទោសទណ្ឌតាមផ្លូវតុលាការ ។

**មាត្រា ៧៧.-**

រដ្ឋបាលគយមានសិទ្ធិសម្រុះសម្រួល ចំពោះបទល្មើសគយដែលមានចែងក្នុងច្បាប់នេះ ។ សិទ្ធិសម្រុះសម្រួលនេះ ប្រើប្រាស់ចំពោះតែការពិន័យជាប្រាក់តែប៉ុណ្ណោះ ។ ក្នុងករណីមិនអាចសម្រុះសម្រួលបានរដ្ឋបាលគយ ត្រូវបញ្ជូនសំណុំរឿងនេះទៅតុលាការមានសមត្ថកិច្ច ។

ការសម្រុះសម្រួលអាចធ្វើទៅបាន នៅមុនពេលមានសាលក្រមរបស់តុលាការមានសមត្ថកិច្ច ។

ល័ក្ខខ័ណ្ឌសម្រាប់អនុវត្តសិទ្ធិក្នុងការសម្រុះសម្រួលត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL



44/45

## ជំពូកទី ១២

## អន្តរប្បញ្ញត្តិ

**មាត្រា ៧៨.–**

ការអនុវត្តបញ្ញត្តិដូចមានចែងក្នុងមាត្រា ២១ និងមាត្រា ២២ នៃច្បាប់នេះ ដែលពាក់ព័ន្ធនឹងការកំណត់តម្លៃពិតពន្ធគយអាចត្រូវបានពន្យារតាមកាលៈទេសៈជាក់ស្តែង ។

## ជំពូកទី ១៣

## អវសានប្បញ្ញត្តិ

**មាត្រា ៧៩.–**

បទប្បញ្ញត្តិនានាទាំងឡាយណា ដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៨០.–**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី *២០* ខែ*កក្កដា* ឆ្នាំ ២០០៧

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

*នស/រកម.០៧០៧.៣១០*

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

**ហត្ថលេខា**

**ហ៊ុន សែន**

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**ហត្ថលេខា**

**គាត ឈន់**

លេខៈ ៣០៤ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែកក្កដា ឆ្នាំ២០០៧

**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ឃុន ឌិនគេន**